មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

កញ្ញា ២០១៤

# របាយការណ៍លទ្ធផល នៃកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ បន្ទាប់ពីការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ ឆ្នាំ២០១៤



ឧបត្ថម្ភដោយ ៖

CIVICUS
World Alliance for Citizen Participation

ifex

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ជាអង្គការមិនមែនរដ្ឋាភិបាល («អង្គការ») មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា»)។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឲ្យកម្ពុជាក្លាយទៅជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសមភាព និងត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក ចង់បាននីតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដែលក្នុងនោះ ភាពចម្រុះបែបត្រូវបានទទួលយក និងសាទរ ជាជាងការព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចឲ្យឃើញរូបសត្វ ព្រាប ស ហើរចេញពីរង្វង់មូលនៃផ្ទៃពណ៌ខៀវ ដែលនេះជានិមិត្តរូបនៃការទាមទារ សេរីភាពរបស់កម្ពុជា។

របាយការណ៍នេះសង្ខេបបទបង្ហាញ ការពិភាក្សារបស់វាគ្មិន និងការពិភាក្សាក្រុមតូចផ្សេងៗ ដែលបានធ្វើឡើងក្នុងអំឡុងពេល នៃកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ បន្ទាប់ពីការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ (យូភីអ) ឆ្នាំ២០១៤ ដែលរៀបចំឡើងដោយ ម.ស.ម.ក និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះរៀបចំដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា តាមរយៈអង្គការផ្តួចផ្តើមលំហាការចូលរួមរបស់ពលរដ្ឋ ដែលបានអនុវត្តក្នុងភាពជាដៃគូជាមួយ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់មិនស្វែងរកប្រាក់កម្រៃ, អង្គការមាត្រា ១៩, ស៊ីវិកខាស ៖ សម្ព័ន្ធពិភពលោកនៃការចូលរួមរបស់ពលរដ្ឋ និងចលនាពិភពលោកដើម្បីលទ្ធិប្រជាធិបតេយ្យ។ របាយការណ៍នេះទទួលបានកិច្ចឧបត្ថម្ភគាំទ្រទាំងមូល ឬដោយផ្នែកពីរដ្ឋាភិបាលប្រទេសស៊ុយអែត។ រដ្ឋាភិបាលប្រទេសស៊ុយអែត មិនរួមចំណែកចំពោះយោបល់ដែលបានបញ្ចេញនៅក្នុងរបាយការណ៍នេះទេ។ របាយការណ៍នេះ ក៏ទទួលបានការឧបត្ថម្ភដោយ អាយហ្វិក ដែលជាបណ្តាញពិភពលោកនៃអង្គការដែលធ្វើការការពារ និងលើកកម្ពស់សេរីភាពបញ្ចេញមតិ ដែលមាន ម.ស.ម.ក ជាសមាជិក។ អ្នកនិពន្ធទទួលខុសត្រូវទាំងស្រុងចំពោះខ្លឹមសារក្នុងរបាយការណ៍នេះ។

## សំណួរ និងយោបល់ត្រឡប់

ប្រសិនបើអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់យោបល់ត្រឡប់ សូមផ្ញើអ៊ីម៉ែល មក ម.ស.ម.ក តាមរយៈ info@cchrcambodia.org។ មួយវិញទៀត សូមទាក់ទង ម.ស.ម.ក តាមរយៈ៖


អាសយដ្ឋានផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

អ៊ីម៉ែល ៖ info@cchrcambodia.org

ទូរសព្ទ ៖ +855 (0) 23 72 69 01

ទូរសារ ៖ +855 (0) 23 72 69 02

វេបសាយ ៖ www.cchrcambodia.org



CC BY NC SA

# មាតិកា

**សេចក្តីផ្តើម** ..... 2

*សាវតានៃការពិគ្រោះយោបល់* ..... 2

*គោលបំណង* ..... 3

**ដំណើរការ** ..... 4

១. **សុន្ទរកថាបើក** ..... 4

*លោកស្រី ជរ ច័ន្ទធីតា, អ្នកស្រាវជ្រាវជាន់ខ្ពស់, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា* ..... 4

*លោកស្រី វ៉ាន់ ហ៊ីលី, តំណាងឧត្តមស្នងការអង្គការសហប្រជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា* ..... 4

*ឯកឧត្តម ម៉ក់ សម្បត្តិ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា* ..... 5

២. **"ទិដ្ឋភាពទូទៅនៃដំណើរការ យូភីអ និងអនុសាសន៍ យូភីអ សម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៤** ..... 6

៣. **ការពិភាក្សាពេញអង្គជាមួយវាគ្មិនៈ "ការអនុវត្តអនុសាសន៍ យូភីអ"** ..... 9

៤. **"ការបង្កើតផែនការតស៊ូមតិជាយុទ្ធសាស្រ្តក្នុងដំណើរការ យូភីអ"** ..... 13

៥. **"ដំណើរការ យូភីអ"** ..... 16

**ការពិភាក្សាជាក្រុម និង អនុសាសន៍** ..... 20

*សេរីភាពខាងការបញ្ចេញមតិ* ..... 20

*កំណែទម្រង់តុលាការ* ..... 21

*សិទ្ធិដីធ្លី* ..... 22

*សិទ្ធិស្រ្តី និងកុមារ* ..... 23

*សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌* ..... 24

**សេចក្តីសន្និដ្ឋាន** ..... 27

ឧបសម្ព័ន្ធទី១ ៖ អនុសាសន៍ដែលផ្តល់អាទិភាពដោយអ្នកចូលរួម ..... 28

ឧបសម្ព័ន្ធ២ ៖ របៀបវារៈនៃការពិគ្រោះយោបល់ ..... 29

ឧបសម្ព័ន្ធទី៣ ៖ អង្គការចូលរួម ..... 31

# សេចក្តីផ្តើម

### *សារតានៃការពិគ្រោះយោបល់*

ក្នុងខែមិថុនា ឆ្នាំ២០១៤ ក្រុមប្រឹក្សាសិទ្ធិមនុស្ស («ក.ប.ស») អង្គការសហប្រជាជាតិ («អ.ស.ប») បានបើកសម័យប្រជុំលើកទី ២៦ របស់ខ្លួន។ ក្នុងអំឡុងពេលសម័យប្រជុំនោះ របាយការណ៍របស់ក្រុមការងារ[1] នៃដំណើរការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ («យូភីអ») របស់កម្ពុជា ត្រូវបានអនុម័តជាផ្លូវការ។ ក្នុងចំណោមអនុសាសន៍ទាំង ២០៥ ដែលរដ្ឋជាសមាជិក អ.ស.ប បានផ្តល់ឲ្យរាជរដ្ឋាភិបាលកម្ពុជា («រដ្ឋាភិបាល») នោះ រដ្ឋាភិបាលសម្រេចទទួលយកចំនួន ១៦៣ និងកត់សម្គាល់ចំនួន ៤២ ។



ទោះនេះ ជាដំណើរការថ្មីមួយក៏ដោយ ក៏ យូភីអ ជាវិធីសាស្ត្រសំខាន់មួយ សម្រាប់វាយតម្លៃលើកំណត់ត្រា បញ្ហាសិទ្ធិមនុស្សរបស់រដ្ឋណាមួយ។ ដោយ សារតែដំណើរការនេះ ជាការវាយតម្លៃពីរដ្ឋដូចគ្នា (មានន័យថារដ្ឋសមាជិក អ.ស.ប ជាអ្នកត្រួតពិនិត្យទៅលើដំណើរការ ទើប មាន ការយល់ឃើញជាច្រើនថា នេះជាដំណើរការវាយតម្លៃមួយដែលមានភាពយុត្តិធម៌ និងមានសមភាព។ ទោះបីជា យូភីអ ជាដំណើរការមិនចងកាតព្វកិច្ចក៏ដោយ ក៏តាមរយៈការជ្រើសរើសទទួលយកអនុសាសន៍នោះ រដ្ឋនីមួយៗត្រូវធ្វើការប្តេជ្ញាចិត្តនៅលើឆាកអន្តរជាតិក្នុងការអនុវត្តអនុសាសន៍ទាំងនោះ ក្នុងអំឡុងពេល ៤ ឆ្នាំដែលជាវដ្ត របស់ យូភីអ ផងដែរ។

ដោយហេតុនេះហើយបានជា ម.ស.ម.ក និងការិយាល័យឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ និងសិក្ខាសាលាតស៊ូមតិ បន្ទាប់ពីការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់របស់កម្ពុជា "កិច្ចពិគ្រោះយោបល់" នៅភ្នំពេញកាលពីថ្ងៃទី១៧ និង ១៨ ខែ

[1] ក្រុមប្រឹក្សាសិទ្ធិមនុស្ស, "របាយការណ៍របស់ក្រុមការងារស្តីពីការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់" (២៧ មិនា ២០១៤) http://bit.ly/1Ajhusn

កក្កដា ឆ្នាំ២០១៤[2]។ អ្នកដែលត្រូវបានអញ្ជើញឲ្យចូលរួមភាគច្រើនមកពីអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការផ្តោតទៅលើសេរីភាពខាងការបញ្ចេញមតិ កំណែទម្រង់តុលាការ សិទ្ធិដីធ្លី សិទ្ធិស្ត្រី និងសិទ្ធិកុមារ និងសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌។ តាមរយៈ កិច្ចពិភាក្សាពេញអង្គ បទបង្ហាញ និងការពិភាក្សាដែលបានរៀបចំឡើងនៅក្នុង កិច្ចពិគ្រោះយោបល់នេះ យើងសង្ឃឹមថាអ្នកចូលរួមនឹងយល់ដឹងកាន់តែប្រសើរអំពីដំណើរការ យូភីអ ក៏ដូចជាអំពីរបៀបតស៊ូមតិ ដើម្បីឲ្យរដ្ឋាភិបាលអនុវត្តនូវអនុសាសន៍ដែលខ្លួនបានទទួលយកទាំងនោះឲ្យមានប្រសិទ្ធភាព។

## *គោលបំណង*

កិច្ចពិគ្រោះយោបល់នេះ ជាឱកាសមួយសម្រាប់សមាជិកអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងធ្វើការនៅក្នុងវិស័យផ្សេងៗ តែផ្តោតសំខាន់ស្មើគ្នាទៅលើសិទ្ធិមនុស្ស បានមកជួបគ្នា និងពិភាក្សាអំពីដំណើរការ យូភីអ របស់កម្ពុជា ក៏ដូចជាដើម្បីទទួលបានចំណេះដឹងបន្ថែមអំពីដំណើរការយូភីអ តាមរយៈបទបង្ហាញ និងការពិភាក្សាជាមួយវាគ្មិន ព្រមទាំងពិភាក្សាអំពីគំនិតរបស់ខ្លួនក្នុងការតាមដានត្រួតពិនិត្យ និងការតស៊ូមតិឲ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍។

គោលបំណងសំខាន់ៗនៃកិច្ចពិគ្រោះយោបល់មានដូចខាងក្រោម ៖

- លើកកម្ពស់ការយល់ដឹងអំពីដំណើរការ យូភីអ ក្នុងចំណោមអង្គការសង្គមស៊ីវិល និងដៃគូពាក់ព័ន្ធ ដើម្បីធានាឲ្យមានការតស៊ូមតិជាប្រព័ន្ធក្នុងការតាមដានការអនុវត្តអនុសាសន៍ក្នុងរយៈពេលបន្ទាប់ៗទៀត និង
- ពិភាក្សាមធ្យោបាយក្នុងការតាមដានការអនុវត្តអនុសាសន៍ យូភីអ របស់រដ្ឋាភិបាល។

[2] ម.ស.ម.ក, "ម.ស.ម.ក និង ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស រៀបចំ កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ និងសិក្ខាសាលាតស៊ូមតិ បន្ទាប់ពីការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់របស់កម្ពុជា" (សេចក្តីប្រកាសព័ត៌មាន) (ថ្ងៃទី១៦ កក្កដា ២០១៤)

# ដំណើរការ

## ១. សុន្ទរកថាបើក

*លោកស្រី ជរ ច័ន្ទធីតា, អ្នកស្រាវជ្រាវជាន់ខ្ពស់, មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា*

លោកស្រី ជរ ច័ន្ទធីតា បានថ្លែងអំណរគុណដល់វាគ្មិន និងអ្នកចូលរួមដែលបានចូលរួមក្នុងកម្មវិធី។ លោកស្រីបានកត់សម្គាល់ថា រដ្ឋជាសមាជិកបានផ្តល់អនុសាសន៍ចំនួន ២០៥ ដល់កម្ពុជា ហើយកាលពីខែមុន កម្ពុជាសម្រេចទទួលយកអនុសាសន៍ចំនួន ១៦៣។ លោកស្រីផ្តល់នូវការពន្យល់ខ្លីមួយអំពីដំណើរការ យូភីអ និងបានឆ្លុះបញ្ចាំងថា ប្រទេសកម្ពុជាប្រហែលជាយកចិត្តទុកដាក់ម៉ត់ចត់អំពីដំណើរការក្នុងលើកទីពីរនេះ។ សម្រាប់លើកទីមួយ កម្ពុជាបានទទួលយកអនុសាសន៍ទាំងអស់ ប៉ុន្តែមិនបានប្រឹងប្រែងខ្លាំងក្នុងការអនុវត្តនោះទេ។ សម្រាប់រយៈពេលពីរថ្ងៃនេះ គោលបំណងរបស់យើងគឺលើកកម្ពស់ការយល់ដឹងអំពីដំណើរការ យូភីអ ក្នុងសង្គមកម្ពុជា និងបង្កើតឲ្យមានយុទ្ធសាស្ត្រតស៊ូមតិដើម្បីជួយកម្ពុជាក្នុងការអនុវត្តអនុសាសន៍ទាំងនោះ។

*លោកស្រី វ៉ាន់ ហ៊ីលី, តំណាងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា*

លោកស្រី វ៉ាន់ ហ៊ីលី បានចាប់ផ្តើមដោយលើកឡើងថា លោកស្រីមានសេចក្តីសោមនស្សរីករាយដែលបានធ្វើការជាថ្មីម្តងទៀតជាមួយ ម.ស.ម.ក។ លោកស្រីថ្លែងអំពីទិដ្ឋភាពទូទៅរបស់ យូភីអ ដែលជាដំណើរការមួយមានយុត្តិធម៌ និងមានការចូលរួមពីរដ្ឋ ដែលអនុញ្ញាតឲ្យរដ្ឋនីមួយៗបង្ហាញអំពីវិធានការដែលរដ្ឋបានធ្វើ ដើម្បីកែលម្អស្ថានភាពសិទ្ធិមនុស្សក្នុងរដ្ឋខ្លួន។ លោកស្រីថ្លែងថា នេះជាដំណើរការមួយមានតម្លាភាព ដោយសារតែឯកសារទាំងអស់ត្រូវដាក់បង្ហាញលើប្រព័ន្ធអ៊ីនធឺណែត ហើយគេក៏អាចមើលរាល់សម័យប្រជុំត្រួតពិនិត្យឡើងវិញរបស់រដ្ឋនីមួយៗនៅតាមប្រព័ន្ធអ៊ីនធឺណែតដែរ។

លោកស្រី វ៉ាន់ ហ៊ីលី បានថ្លែងសង្កត់ធ្ងន់ថា អង្គការមិនមែនរដ្ឋាភិបាល មានតួនាទីសំខាន់ណាស់ក្នុងដំណើរការនេះ ហើយការដែលរដ្ឋអនុវត្តអនុសាសន៍ ឬមិនអនុវត្តនោះ ភាគច្រើនអាស្រ័យលើការតស៊ូមតិរបស់អង្គការ និងអាស្រ័យលើឥទ្ធិពលរបស់អង្គការមិនមែនរដ្ឋាភិបាលថាមានកម្រិតខ្លាំងប៉ុណ្ណា។ ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស គាំទ្រសិក្ខាសាលានេះ ហើយក៏បានរៀបចំវគ្គបណ្តុះបណ្តាលអង្គការនានា អំពីរបៀបដាក់របាយការណ៍នៅក្នុងដំណើរការ យូភីអ ផងដែរ។ លោកស្រីក៏បានរំលឹកដល់អ្នកចូលរួមអំពីសារៈសំខាន់នៃការតាមដានបន្ត។ ប្រសិនបើមិនមានការតាមដានបន្តរួមគ្នាដោយម៉ត់ចត់ទៅលើ យូភីអ ទេនោះ រាល់កិច្ចខំប្រឹងប្រែងរបស់ រដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកផ្សេងទៀតចំពោះដំណើរការ យូភីអ នេះនឹងមិនបានទទួលជោគជ័យឡើយ។ ដូច្នេះភាគីពាក់ព័ន្ធទាំងអស់ត្រូវខិតខំប្រឹងប្រែងចូលរួមក្នុងការតាមដានបន្តនៅពេលនេះ។

លោកស្រី វ៉ាន់ ហ៊ីលី ក៏បានផ្តល់យោបល់ទៅលើគំនិតដែលថាអនុសាសន៍ យូភីអ នេះមិនចងកាតព្វកិច្ចផ្លូវច្បាប់ទេ។ លោកស្រី បានពន្យល់ថា នៅពេលដែលអនុសាសន៍ទាំងនោះ ប៉ះលើបញ្ហាដែលគ្របដណ្តប់នៅក្នុងសន្ធិ-សញ្ញាអន្តរជាតិដែលមានចងកាតព្វកិច្ចផ្លូវច្បាប់ ប្រាកដណាស់ថាអនុសាសន៍ទាំងនោះត្រូវតែអនុវត្ត។ ជាការពិតណាស់ ការទទួលខុសត្រូវសម្រាប់ការអនុវត្តជាបន្ទុករបស់រដ្ឋាភិបាល ប៉ុន្តែសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់មួយក្នុងការជួយ និងតាមដានត្រួតពិនិត្យការអនុវត្តនោះ។

*ឯកឧត្តម ម៉ក់ សម្បត្តិ ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា*

ឯកឧត្តម ម៉ក់ សម្បត្តិ សម្តែងក្តីអំណរគុណដល់ ម.ស.ម.ក ក្នុងការរៀបចំសិក្ខាសាលានេះ និងបង្ហាញនូវក្តីសង្ឃឹមរបស់លោកថា សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល នឹងយល់កាន់តែច្បាស់អំពីដំណើរការ យូភីអ នេះ។ លោកបានថ្លែងថា សង្គមស៊ីវិលគឺជាដៃគូរបស់រដ្ឋាភិបាល ហើយលោកចង់ឃើញពួកគេទទួលបានជោគជ័យ។ លោកកត់សម្គាល់ផងដែរថា គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) ដើរតួនាទីសម្របសម្រួល ដោយធ្វើការជាមួយសង្គមស៊ីវិល។




ពាក់ព័ន្ធនឹង ដំណើរការ យូភីអ នេះ លោកបានថ្លែងថា មុនឆ្នាំ ២០០៦ ដំណើរការនេះមិនទាន់មាន នៅឡើយទេ ដូច្នេះហើយ គេយល់ឃើញថាការពិនិត្យលើ សិទ្ធិមនុស្សនេះ មានលក្ខណៈមិនសមភាព និងមិនយុត្តិធម៌ ដោយសារតែគេភាគច្រើន ផ្តោតតែលើប្រទេសកំពុងអភិវឌ្ឍ និងជ្រើសរើស ប្រទេសចំនួនប្រហែលតែ១០ ប៉ុណ្ណោះ សម្រាប់ផ្តល់អនុសាសន៍។ ឥឡូវនេះមានប្រទេសចំនួន ១៩៣ ដែល ប្រទេសទាំងអស់នេះអាចមានសិទ្ធិត្រូវបានជ្រើសរើសក្លាយជាសមាជិកទាំង ៤៧ នៅក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្ស (ក.ប.ស) ក្នុងមួយពេល (មានប្រទេសចំនួន ១៣ មកពីទ្វីបអាហ្វ្រិក ប្រទេសចំនួន ១៣ មកពីទ្វីបអាស៊ីប៉ាស៊ីហ្វិក ប្រទេសចំនួន ៨ មកពីទ្វីបអាមេរិចឡាទីន និងតំបន់ការ៉ាបៀន និង ប្រទេសចំនួន ៧ មកពីទ្វីបអឺរ៉ុបខាងលិច និងតំបន់ផ្សេងៗទៀត)។

លោកកត់សម្គាល់ថា ក្នុងអំឡុងពេល យូភីអ លើកមុន ប្រទេសកម្ពុជាទទួលបានអនុសាសន៍ ៩១ ហើយរដ្ឋា-ភិបាលទទួលយកទាំងអស់ ដោយសារតែភាគច្រើនអនុសាសន៍ទាំងនោះមាននៅក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ

ជាតិរួចទៅហើយ។ តែនៅពេលនេះ រដ្ឋាភិបាលទទួលអនុសាសន៍ ១៦៣ និងកត់សម្គាល់ចំនួន ៤២ អនុសាសន៍ទាំងនោះត្រូវតែពិភាក្សាមុនពេលភាគីពាក់ព័ន្ធអាចធ្វើអ្វីបាន ដូច្នេះហើយលោកថ្លែងថា លោកសប្បាយចិត្តណាស់ដែលបានចូលរួមក្នុងសិក្ខាសាលានេះ។ លោកជឿថា ជារឿងសំខាន់ណាស់ ដែលមនុស្សគ្រប់គ្នាធ្វើការរួមគ្នា។ រដ្ឋាភិបាលកម្ពុជា នឹងបន្តធ្វើការអនុវត្តអនុសាសន៍ទាំងនោះ ប៉ុន្តែប្រសិនបើមានអនុសាសន៍ច្រើនពេក នោះនឹងមានការពិបាកក្នុងការអនុវត្តអនុសាសន៍ទាំងនោះផងដែរ។

លោក សម្បត្តិ ក៏បានរៀបរាប់អំពីរបាយការណ៍របស់រដ្ឋាភិបាល ដែលបានដាក់ទៅកាន់ យូភីអ នេះ ដែលរួមមានបួនផ្នែកៈ សេចក្តីផ្តើមនៃរបាយការណ៍, សមិទ្ធិផល និងវិធានការដែលរដ្ឋាភិបាលយកទៅអនុវត្ត, បញ្ហាប្រឈម, និងការធ្វើការរបស់រដ្ឋាភិបាលក្នុងពេលអនាគត។ លោកកត់សម្គាល់ថា យូភីអ គឺជាដំណើរការដ៏សំខាន់ ដែលរដ្ឋាភិបាលត្រូវតែបញ្ជូនរបាយការណ៍នេះ ដោយសារជាការតម្រូវជាចាំបាច់ចំពោះរដ្ឋនីមួយៗ ហើយរដ្ឋនីមួយៗក៏មិនអាចគេចវេស ឬពន្យារពេលបញ្ជូនរបាយការណ៍ ដូចដែលធ្លាប់បានធ្វើចំពោះដំណើរការពិនិត្យ នៃ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ («ក.អ.ស.ព.ន») និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ («ស៊ី ដ») នោះទេ។ លោកថ្លែងបញ្ចប់ដោយគូសបញ្ជាក់សង្កត់ធ្ងន់អំពីសេចក្តីប្រាថ្នារបស់លោកចង់ឃើញអ្នកចូលរួម ចូលរួមយ៉ាងសកម្ម យកចិត្តទុកដាក់ស្តាប់បទបង្ហាញ និងរកឲ្យបាននូវអ្វីដែលអាចធ្វើបានពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការរវាងសង្គមស៊ីវិល និងរដ្ឋាភិបាល។

## ២. "ទិដ្ឋភាពទូទៅនៃដំណើរការ យូភីអ និងអនុសាសន៍ យូភីអ សម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៤

*បទបង្ហាញដោយលោកស្រី ខាធីរីន ភួង អ្នកសម្របសម្រួលកម្មវិធីនីតិរដ្ឋ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា*

លោកស្រី ខាធីរីន ភួង បង្ហាញអំពីទិដ្ឋភាពទូទៅនៃការបង្កើតដំណើរការ យូភីអ។ សេចក្តីសម្រេចមហាសន្និបាត អ.ស.ប លេខ ៦០/២៥១ បានបង្កើត ក.ប.ស ជំនួសឲ្យគណៈកម្មាធិការសិទ្ធិមនុស្ស និងមានអាណត្តិក្នុងការ ធ្វើការ "ត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់"។

លោកស្រី ភួង បានពន្យល់អំពីគោលបំណងរបស់ យូភីអ ដែលរួមមាន (១) កែលម្អស្ថានភាពសិទ្ធិមនុស្សនៅមូលដ្ឋាន, (២) បំពេញកាតព្វកិច្ច និងការប្តេជ្ញាចិត្តរបស់រដ្ឋផ្នែកសិទ្ធិមនុស្ស, (៣) ពង្រឹងសមត្ថភាពរបស់រដ្ឋតាមរយៈជំនួយបច្ចេកទេស, (៤) ការចែករំលែកការអនុវត្តល្អៗបំផុតក្នុងចំណោមរដ្ឋទាំងឡាយ និងភាគីពាក់ព័ន្ធផ្សេងៗ, (៥) គាំទ្រដល់កិច្ចសហប្រតិបត្តិការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស, និង (៦) កិច្ចសហប្រតិបត្តិការ

ពេញលេញជាមួយក្រុមប្រឹក្សា ជាមួយស្ថាប័នសិទ្ធិមនុស្សដទៃទៀត និងជាមួយ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស។

បន្ទាប់មក លោកស្រីភួង បានបង្ហាញអំពីគោលការណ៍សំខាន់ៗរបស់ យូភីអ ដែលរួមមាន ៖

1. សាកលភាព - រាល់សិទ្ធិមនុស្សទាំងអស់ (សិទ្ធិពលរដ្ឋ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌) ត្រូវបានត្រួតពិនិត្យ
2. ភាពមិនរើសអើង - រដ្ឋសមាជិក អ.ស.ប ទាំងអស់ ត្រូវបានត្រួតពិនិត្យទៅលើកំណត់ត្រាផ្នែកសិទ្ធិមនុស្សទាំងអស់របស់រដ្ឋនោះ និង
3. សមភាព - ការត្រួតពិនិត្យឡើងវិញនេះ ត្រូវធ្វើឡើងដូចគ្នាសម្រាប់គ្រប់រដ្ឋទាំងអស់។

លោកស្រីបានលើកឡើងថា យូភីអ ជាយន្តការសហប្រតិបត្តិការ ហើយយន្តការនេះមិនជំនួសឲ្យអ្នកតំណាងពិសេស ឬយន្តការសិទ្ធិមនុស្សដទៃទៀតឡើយ។

បន្ទាប់មក លោកស្រីភួង បានពិភាក្សាអំពីមូលដ្ឋានច្បាប់នៃការត្រួតពិនិត្យនេះ ដែលចេញមកពីធម្មនុញ្ញរបស់ អ.ស.ប សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស («ស.ប.ស.ស») សន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗដែលរដ្ឋកំពុងត្រូវគេត្រួតពិនិត្យនេះផ្តល់សច្ចាប័ន ការសន្យា និងការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្តណាមួយដែលរដ្ឋបានធ្វើ (ទាំងថ្នាក់ជាតិ និងអន្តរជាតិ) ព្រមទាំងច្បាប់មនុស្សធម៌អន្តរជាតិដែលអាចអនុវត្តបាន។

លោកស្រីក៏បានពន្យល់ដែរអំពីមូលដ្ឋានឯកសារដែលត្រូវធ្វើការពិនិត្យនេះ ដោយកើតចេញពី របាយការណ៍ដូចជា របាយការណ៍ជាតិ (រៀបចំដោយរដ្ឋដែលនឹងត្រូវបានគេពិនិត្យ ចំនួន ២០ ទំព័រ), ឯកសារចងក្រងដោយ អ.ស.ប (រៀបចំដោយ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយផ្អែកលើព័ត៌មានរបស់ អ.ស.ប ចំនួន ១០ ទំព័រ), និងសេចក្តីសង្ខេបរបស់ភាគីពាក់ព័ន្ធ (រៀបចំដោយ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលផ្តល់ឲ្យដោយភាគីពាក់ព័ន្ធផ្សេងៗ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ និងអង្គការថ្នាក់តំបន់ចំនួន ១០ ទំព័រ)។

លោកស្រីភួង បានកត់សម្គាល់ថាមានការរីកចម្រើនមួយចំនួនក្នុងប្រទេសកម្ពុជាចាប់តាំងពីវដ្ត យូភីអ ដំបូងមក។ នាពេលបច្ចុប្បន្ននេះ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា («គ.ស.ម.ក») ទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្តអនុសាសន៍ដែលបានធ្វើឡើងក្នុងអំឡុងពេល យូភីអ។ ជាងនេះទៀត អនុសាសន៍ យូភីអ ឥឡូវត្រូវបានគេបែងចែកទៅឲ្យក្រសួងពាក់ព័ន្ធនីមួយៗ ដែលត្រូវធ្វើរបាយការណ៍ពាក់កណ្តាលវដ្តដល់ គ.ស.ម.ក អំពីស្ថានភាពនៃការអនុវត្ត។

លោកស្រីភួង បានកត់សម្គាល់អំពីបញ្ហាប្រឈមទាក់ទងនឹងការអនុវត្តអនុសាសន៍ យូភីអ នៅកម្ពុជា ដូចជា អនុសាសន៍មានច្រើនពេក, អនុសាសន៍ភាគច្រើនមានភាពស្រពេចស្រពិល និងពិបាកក្នុងការអនុវត្ត, បញ្ហាធនធាន

និងអ្នកជំនាញក្នុង គ.ស.ម.ក, បញ្ហាទាក់ទងនឹងកង្វះការប្រាស្រ័យទាក់ទងរវាងក្រសួងផ្សេងៗ និងការផ្តោតការយកចិត្តទុកដាក់ខ្លាំងពេកតែទៅលើការធ្វើរបាយការណ៍។ លោកស្រីក្លួង បានសង្កត់ធ្ងន់ថា ផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការអនុវត្តន៍ ជាជាងទៅលើការធ្វើរបាយការណ៍ ដោយលោកស្រីបានកត់សម្គាល់ថា លទ្ធផលអនុវត្តល្អតែងធ្វើឲ្យការធ្វើរបាយការណ៍សម្រាប់វដ្តបន្ទាប់កាន់តែមានភាពងាយស្រួល។

ពាក់ព័ន្ធនឹងសារៈសំខាន់នៃរបាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល លោកស្រីក្លួង ថ្លែងថាសមាជិករបស់ ក.ប.ស ប្រហែលជាមិនធ្លាប់មកទស្សនាប្រទេសកម្ពុជាទេ ដូចនេះ ពួកគេពឹងផ្អែកទាំងស្រុងទៅលើរបាយការណ៍ដែលសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដាក់ទៅ។

ពាក់ព័ន្ធនឹងអនុសាសន៍ឆ្នាំនេះ ដែលកម្ពុជាទទួលយកអនុសាសន៍ ចំនួន ១៦៣ និងកត់សម្គាល់ ចំនួន ៤២ នោះ លោកស្រីបានពន្យល់ថា រដ្ឋមិនអាច "បដិសេធ" អនុសាសន៍ណាមួយបានទេ ដូច្នេះអនុសាសន៍ទាំង ៤២ ដែលកម្ពុជាមានបំណង "បដិសេធ" ត្រូវកត់ត្រាថាជាការ "កត់សម្គាល់" វិញ។ ការកត់សម្គាល់ទៅលើអនុសាសន៍ណាមួយមានន័យថារដ្ឋដែលកំពុងត្រូវបានត្រួតពិនិត្យនោះ មិនបានប្តេជ្ញាអនុវត្តអនុសាសន៍នោះទេ ដូចនេះមានន័យថាអង្គការសង្គមស៊ីវិលត្រូវផ្តោតការងាររបស់ពួកគេទៅលើអនុសាសន៍ ១៦៣ ដែលកម្ពុជាយល់ព្រមអនុវត្ត។ បន្ថែមលើនេះ លោកស្រីក្លួង បានជំទាស់ទៅនឹងគំនិតដែលថា ការដែលមានអនុសាសន៍ច្រើនជាវដ្តមុន មានន័យថាកម្ពុជាមានស្ថានភាពអាក្រក់ជាងមុននោះទេ។ លោកស្រីកត់សម្គាល់ថា ទោះបីជាមានការផ្តល់អនុសាសន៍ច្រើនក៏ដោយ ក៏អនុសាសន៍ជាច្រើនគ្របដណ្តប់លើបញ្ហាដូចគ្នា។

បន្ទាប់មក លោកស្រីលើកឡើងអំពីបញ្ហាផ្សេងៗគ្នាដែលមាននៅក្នុងអនុសាសន៍ទាំងនោះ ដូចជា ការផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាផ្សេងៗ កំណែទម្រង់ច្បាប់ ការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិ កិច្ចសហប្រតិបត្តិការផ្នែកបច្ចេកទេស ស្ត្រីនិងកុមារ កំណែទម្រង់ច្បាប់ និងតុលាការ សេរីភាពជាមូលដ្ឋាន ដីធ្លី និងបញ្ហាសេដ្ឋកិច្ច និងសង្គម។

លោកស្រីបានថ្លែងបញ្ចប់ ដោយកត់សម្គាល់ថា ការចាប់ផ្តើមតាមដានការវិវឌ្ឍន៍នៃការអនុវត្តអនុសាសន៍តាំងពីដំបូងទៅ មានសារៈសំខាន់ណាស់ ហើយអ្នកចូលរួមត្រូវមានសកម្មភាព និងផែនការរឹងមាំក្នុងការតាមដានការអនុវត្តនេះ និងត្រូវផលិតព័ត៌មានពាក់ព័ន្ធ។ លោកស្រីបានសង្កត់ធ្ងន់អំពីសារៈសំខាន់ដែលត្រូវមានឯកសារ និងទិន្នន័យដើម្បីឲ្យឃើញថាតើអនុសាសន៍ជាក់លាក់ទាំងឡាយនោះត្រូវបានអនុវត្តដែរឬទេ។ រដ្ឋាភិបាល បានទទួលយកអនុសាសន៍ទាំងនោះជាសាធារណៈ និងដោយបើកចំហនៅចំពោះមុខ ក្រុមប្រឹក្សាសិទ្ធិមនុស្ស និងនៅលើឆាកសកលលោក ហើយតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល គឺត្រូវបន្តរំលឹករដ្ឋាភិបាលអំពីអ្វីដែលរដ្ឋាភិបាលបានទទួលយក និងត្រូវជួយគាំទ្រតាមលទ្ធភាពសមរម្យដើម្បីឲ្យរដ្ឋាភិបាលអាចអនុវត្តអនុសាសន៍ទាំងនោះបាន។ អនុសាសន៍យូភីអ គួរត្រូវប្រើឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ក្នុងការតស៊ូមតិឲ្យមានកំណែទម្រង់សិទ្ធិមនុស្ស។

## ៣. ការពិភាក្សាពេញអង្គជាមួយខាគ្និនះ "ការអនុវត្តអនុសាសន៍ យូភីអ"

*សម្របសម្រួលដោយ កញ្ញា សន រ៉ាមណា អ្នកសម្របសម្រួលគម្រោងសេរីភាពខាងការបញ្ចេញមតិ, ម.ស.ម.ក*

*លោក មាស សំណាង អគ្គលេខាធិការ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ*

លោក មាស សំណាង បានចាប់ផ្តើមដោយពន្យល់អំពីគោលបំណងរបស់ សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (ស.អ.ស.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល មានគោលបំណងក្នុងការផ្តល់ជំនួយបច្ចេកទេស និងការគាំទ្រដល់អង្គការជាសមាជិក និងមានគោលបំណងលើកកម្ពស់ និងតស៊ូមតិដើម្បីសិទ្ធិកុមារនៅកម្ពុជា។ លោកបានសង្កត់ធ្ងន់ថា ការពិគ្រោះយោបល់ពិតជាមានសារៈសំខាន់ណាស់សម្រាប់ធ្វើការតស៊ូមតិនៅថ្នាក់ជាតិទៅលើបញ្ហាទាំងឡាយដែលបានលើកឡើងដោយអនុសាសន៍ យូភីអ។

*លោក អ៊ូ វីរៈ ប្រធានក្រុមប្រឹក្សាភិបាល ម.ស.ម.ក*

លោក អ៊ូ វីរៈ លើកឡើងថា ឆ្នាំនេះរដ្ឋាភិបាលទទួលយកអនុសាសន៍១៦៣។ ថ្លែងអំពីអនុសាសន៍ដែលរដ្ឋាភិបាលបានកត់សម្គាល់ លោក អ៊ូ វីរៈ ពន្យល់ថានៅពេលដែលរដ្ឋាភិបាលប្រើពាក្យ "កត់សម្គាល់" នោះជាការបង្ហាញពីអារម្មណ៍នៃការបដិសេធ។ លោក អ៊ូ វីរៈ ក៏បានកត់សម្គាល់ផងដែរថា អនុសាសន៍ជាច្រើនប្រើភាសាលក្ខណៈការទូតខ្លាំងណាស់ ឧទាហរណ៍ តើគេអាចអនុវត្តអនុសាសន៍ដែលលើកឡើងថា "គោរពសិទ្ធិមនុស្ស" បានយ៉ាងដូចម្តេច? លោកបានផ្តល់យោបល់ថា ប្រសិនបើរដ្ឋាភិបាលប្តេជ្ញាចិត្តក្នុងការអនុវត្តអនុសាសន៍មួយចំនួន ហើយរដ្ឋាភិបាលមិនអនុវត្តនោះ រដ្ឋាភិបាលត្រូវគិតអំពីកិត្តិយសរបស់ខ្លួននៅពេលប្រឈមមុខជាមួយនឹងសហគមន៍អន្តរជាតិ។ បន្ថែមពីលើ យូភីអ នេះ កម្ពុជាក៏បានទទួលអនុសាសន៍តាមរយៈយន្តការ អ.ស.ប ផ្សេងៗទៀត ដូចជា កតិកាសញ្ញានានា ហើយរដ្ឋាភិបាលមានទំនួលខុសត្រូវក្នុងការអនុវត្តអនុសាសន៍ទាំងនេះ។ លោក អ៊ូ វីរៈ បានចោទសួរថាហេតុអ្វីបានជាអនុសាសន៍មួយចំនួនដូចគ្នា ហើយចោទសួរថាតើនឹងមានរឿងអ្វីកើតឡើងប្រសិនបើរដ្ឋាភិបាលមិនបានអនុវត្តអនុសាសន៍នោះ។ សំណួរទាំងនេះ ត្រូវការចម្លើយ។

*លោក សួន ប៊ុនសក្តិ លេខាប្រតិបត្តិ គណៈកម្មការប្រព្រឹត្តកម្មអង្គការសមាគមសិទ្ធិមនុស្សនៅកម្ពុជា*

ក្នុងការថ្លែងចាប់ផ្តើមក្នុងក្រុមពិភាក្សានេះ លោក សួន ប៊ុនសក្តិ លើកឡើងថា អ្នកដែលសរសេរសេចក្តីសម្រេចអំពីកម្ពុជានេះ មិនមែនជាចៅក្រមនោះទេ ដូច្នេះ នោះគ្រាន់តែជាអនុសាសន៍ប៉ុណ្ណោះ ហើយជាអកុសល ក៏មិនមាននរណាដើរតួជាប៉ូលីស ឬជាតុលាការដែរ។ លោកកត់សម្គាល់ថា ក្នុងវដ្ត យូភីអ ដំបូង រដ្ឋាភិបាលបានទទួលយកអនុសាសន៍ទាំងអស់ ដែលលោកយល់ថាជាការទទួលទាំងងងឹតងងល់ ហើយលោកក៏បានលើកឡើងដែរថា នៅពេលនោះ រដ្ឋាភិបាលប្រហែលមិនបានដឹងច្បាស់នៅឡើយទេថាដំណើរការនេះធ្វើការយ៉ាងដូចម្តេចនោះ។ នៅ

ពេលដែលកម្ពុជាទទួលយកអនុសាសន៍ទាំង ៩១ នោះ រដ្ឋាភិបាលមិនបានដឹងអំពីរបស់របៀបនៃការអនុវត្តអនុសាសន៍ឲ្យបានជាក់ស្តែងនោះទេ។ លោក សួន ប៊ុនសក្តិ កត់សម្គាល់ថា សង្គមស៊ីវិលមានការចូលរួមច្រើននៅក្នុងវដ្ត ទីពីរនេះ ហើយជំហានបន្ទាប់សម្រាប់សង្គមស៊ីវិល គឺត្រូវពិភាក្សាថាតើអង្គការណាខ្លះអាចធ្វើការតាមដាន និងត្រួត ពិនិត្យទៅលើការអនុវត្តអនុសាសន៍ទាំងនោះ។ អង្គការទាំងឡាយត្រូវការអាន និងព្យាយាមយល់អំពីអនុសាសន៍ ទាំងអស់នោះ ដែលពេលនេះរឹតតែមានការលំបាកដោយសារតែអនុសាសន៍ទាំងនេះមានចំនួនច្រើនជាងកាលពី លើកមុន។ បន្ទាប់ពីអានអនុសាសន៍ទាំងនោះហើយ អង្គការនោះត្រូវជ្រើសរើសអនុសាសន៍ណាដែលត្រូវនឹងវិស័យ របស់ខ្លួនដើម្បីយកទៅធ្វើការតស៊ូមតិ ដើម្បីឲ្យរដ្ឋាភិបាលអនុវត្តនូវអនុសាសន៍ទាំងនោះឲ្យបានជោគជ័យ។ អង្គការ ត្រូវតែធ្វើផែនការសម្រាប់អនុវត្ត។ លោក សួន ប៊ុនសក្តិ ក៏បានថ្លែងអំពីអនុសាសន៍ដែលមិនសូវច្បាស់ដែរ ដោយបាន ចោទសួរថាតើគេរំពឹងថារដ្ឋាភិបាលអាចអនុវត្តអនុសាសន៍ដែលមានភាពមិនច្បាស់លាស់ម្តេចនឹងបាន ដូចជា "ការ ផ្តល់លំនៅឋានសមរម្យ" ជាដើមនោះ។

### *សំណួរ*

អ្នកសម្របសម្រួល និងអ្នកចូលរួមបានលើកឡើងជាសំណួរជាច្រើនដូចខាងក្រោម ៖

- តើអ្នកគិតថាមានបញ្ហាអ្វីខ្លះ ដែលមិនមានគ្របដណ្តប់នៅក្នុងអនុសាសន៍ដែលបានផ្តល់មកនេះដែរឬទេ?
- សម្រាប់វដ្តទីពីរនៃ យូភីអ នេះ តើយើងអាចធ្វើអ្វីបានខ្លះដើម្បីធានាថានឹងមានភាពប្រសើរជាងពីលើកមុន?
- តើវដ្តទីមួយ និងវដ្តទីពីរនៃ យូភីអ នេះ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការមានភាពខុសគ្នាបែបណាខ្លះ?
- តើសង្គមស៊ីវិលមានបានចូលរួមក្នុងសម័យប្រជុំ យូភីអ នេះពីមុនមកដែរឬទេ?
- ប្រសិនបើរដ្ឋាភិបាលមិនអនុវត្តអនុសាសន៍ តើអ្នកណាជាអ្នកពិនិត្យនៅលើពួកគាត់?
- តើយើងគួរគោរពអនុសាសន៍មកពីរដ្ឋដែលមានកំណត់ត្រាសិទ្ធិមនុស្សអន់ជាងប្រទេសកម្ពុជាដែរឬទេ?
- តើអ្នកមានក្តីរំពឹងអ្វីខ្លះចំពោះការអនុវត្តអនុសាសន៍ទាំងនេះ? តើអ្នកអាចប្រមើលមើលដំណើរការអនុវត្តនាពេលអនាគតនឹងមានលក្ខណៈយ៉ាងដូចម្តេច?

### *ការឆ្លើយតបដោយលោក អ៊ូ វីរៈ*

លោក អ៊ូ វីរៈ ជឿថារដ្ឋាភិបាលគួរបដិសេធឬកត់សម្គាល់អនុសាសន៍ច្រើនជាង ៤២ ព្រោះថាអនុសាសន៍មួយ ចំនួនមិនមានប្រយោជន៍អ្វីនោះទេ។ លោកក៏លើកឡើងដែរថា អនុសាសន៍មួយចំនួនត្រូវបានអនុវត្តតែក្នុងនាមជា ការអនុវត្តតែប៉ុណ្ណោះ តែពុំមានស្មារតីពិតប្រាកដនោះទេ ឧទាហរណ៍ ច្បាប់ទាំងបីទាក់ទងវិស័យតុលាការដែលទើប តែត្រូវបានអនុម័តក្នុងពេលកន្លងមកនេះ មានន័យតិចតួចបំផុតក្នុងបរិបទកង្វះឯករាជ្យភាពរបស់តុលាការ។ ការ អនុម័តច្បាប់ទាំងបីនោះ មិនបានចូលរួមក្នុងស្មារតីនៃអនុសាសន៍ដែលមានគោលបំណងកំណែទម្រង់តុលាការនោះ ទេ។

ពាក់ព័ន្ធនឹងការលើកថា មានអនុសាសន៍មួយចំនួនចេញមកពីប្រទេសដែលមានកំណត់ត្រាសិទ្ធិមនុស្សអន់ជាងប្រទេសកម្ពុជានោះ លោក អ៊ូ វីរៈ កត់សម្គាល់ថា នេះមិនមែនមានន័យថារដ្ឋាភិបាលគួរបដិសេធអនុសាសន៍ដែលប្រទេសទាំងនោះលើកឡើងនោះទេ។ បញ្ហានៅត្រង់ថា អនុសាសន៍ទាំងនោះភាគច្រើនមានភាពទូលាយខ្លាំង និងមិនមានប្រយោជន៍។ ប្រការសំខាន់ត្រូវមើលទៅលើអនុសាសន៍ទាំងនោះ។ ប្រសិនបើអនុ សាសន៍នោះល្អសម្រាប់ប្រទេសយើងនោះ រឿងថាប្រទេសណាជាអ្នកផ្តល់អនុសាសន៍នោះ មិនសំខាន់នោះទេ។

*ការឆ្លើយតបដោយ លោក សួន ប៊ុនសក្តិ*

ពាក់ព័ន្ធនឹងសំណួរអំពីការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងដំណើរការ យូភីអ នេះ លោក សួន ប៊ុនសក្តិ បញ្ជាក់ថាអ្នកណាក៏អាចដាក់របាយការណ៍បានដែរ គឺទាំងបុគ្គល ឬ អង្គការមិនមែនរដ្ឋាភិបាល។ លោកពន្យល់ថា ដំណាក់កាលដំបូង គឺត្រូវដាក់របាយការណ៍។ ដំណាក់កាលទីពីរ គឺថារដ្ឋជាសមាជិកត្រូវអានរបាយការណ៍ទាំងអស់ ដើម្បីបង្កើតអនុសាសន៍។ ដំណាក់កាលទីបី គឺសម័យប្រជុំរបស់ក្រុមការងារ ដែលអង្គការសង្គមស៊ីវិលអាចមកស្តាប់បាន ប៉ុន្តែមិនមែនគ្រប់គ្នាដែលបានដាក់របាយការណ៍ត្រូវគេអញ្ជើញនោះទេ។ ចំណែកដំណាក់កាលចុងក្រោយ គឺសម័យប្រជុំពេញអង្គ ដែលគេអនុញ្ញាតឲ្យសង្គមស៊ីវិលចូលរួមបាន តែមិនត្រូវបានអនុញ្ញាតឲ្យនិយាយអ្វីនោះទេ។ អង្គការមិនមែនរដ្ឋាភិបាលអាចនិយាយបាននៅតុកាហ្វេ នៅពេលអាហារថ្ងៃត្រង់ និងពេលសម្រាកដើម្បីធ្វើការបញ្ចុះបញ្ចូល ប៉ុន្តែមិនអាចធ្វើការថ្លែងជាផ្លូវការបាននោះទេ។ លោក សួន ប៊ុនសក្តិ ក៏បានកត់សម្គាល់ផងដែរថា ជាទូទៅរដ្ឋាភិបាលមិនពិចារណាអំពីរបាយការណ៍ដែលសង្គមស៊ីវិលដាក់នោះទេ។ លោកបានលើកឡើងអំពីភាពមិនជឿជាក់ទៅលើការអនុវត្តអនុសាសន៍ទាំង ១៦៣ នោះ ដោយបានកត់សម្គាល់ថា លោកមិនសូវមានភាពវិជ្ជមានប៉ុន្មានទេ ចំពោះក្រុមមេដឹកនាំបច្ចុប្បន្ន នេះ ហើយអ្វីដែលបានកើតឡើងនៅក្នុងវដ្តមុននេះ គឺជាភស្តុតាងបញ្ជាក់ថាអនុ-សាសន៍ទាំងនោះនឹងមិនមានប្រសិទ្ធភាព នោះទេ។ លោកក៏បានកត់សម្គាល់ដែរថា មិនសំខាន់ថាប្រទេសណា ជាអ្នកផ្តល់អនុសាសន៍នោះទេ ប៉ុន្តែ អ្វីដែលសំខាន់គឺអនុសាសន៍នោះទៅវិញទេ។




លោក សួន ប៊ុនសក្តិ ថ្លែងថា ការអនុវត្តពេញលេញ ទៅលើអនុសាសន៍ទាំងនោះ នឹងក្លាយទៅជាសមិទ្ធផលមួយ ហើយនឹងនាំឲ្យមានការផ្លាស់ប្តូរវិជ្ជមាន។ ឧទាហរណ៍ ប្រសិនបើរដ្ឋាភិបាល ជ្រើសរើសថាត្រូវផ្តល់សច្ចាប័នកតិកាសញ្ញាអន្តរជាតិស្តីពីពលកម្មចំណាកស្រុក និងសមាជិកគ្រួសាររបស់ពួកគេ នោះរដ្ឋា

ភិបាលនឹងត្រូវតែការពារកម្មករចំណាកស្រុកដែលមកពីប្រទេសដទៃទៀត។ ក៏ប៉ុន្តែ នៅពេលដែលប្រទេសទាំងនោះមិនផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញានោះ ពួកគេមិនចាំបាច់ទទួលខុសត្រូវក្នុងការគោរពកម្មករកម្ពុជាឡើយ ដូច្នេះជាការសំខាន់ណាស់ដែលត្រូវបញ្ចុះបញ្ចូលប្រទេសផ្សេងៗ ដែលទទួលយកកម្មករកម្ពុជាឲ្យផ្តល់សច្ចាប័នលើសន្ធិ-សញ្ញានេះដែរ។ លោក សួន ប៊ុនសក្តិ លើកឡើងថា លោកគិតថាប្រទេសកម្ពុជាមិនគួរផ្តល់សច្ចាប័នលើកតិកាសញ្ញានេះទេ លុះត្រាតែប្រទេសផ្សេងទៀតផ្តល់សច្ចាប័ននោះផងដែរ។

*ការឆ្លើយតបដោយលោក មាស សំណាង*

លោក មាស សំណាង កត់សម្គាល់ថាការដែលប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍជាអ្នកផ្តល់អនុសាសន៍នោះគឺមិនសំខាន់ទេ សំខាន់ត្រូវមើលទៅលើអនុសាសន៍នោះ និងទៅលើរបៀបអនុវត្តឲ្យមានប្រសិទ្ធភាព។ លោកបានផ្តល់អនុសាសន៍ថា អ្នកចូលរួមគួរមើលរូបភាពធំ ទើបអាចឲ្យពួកគេដោះស្រាយបញ្ហានៅថ្នាក់ជាតិបាន។ ក្រៅពីរបាយការណ៍ដែលលោកស្រីក្អួង បានលើកឡើង ជារបាយការណ៍ទៅកាន់ម្ចាស់ជំនួយនោះ យើងក៏ត្រូវសុំឲ្យពួកគេគាំទ្រដល់កិច្ចខំប្រឹងប្រែងនៃការធ្វើការតស៊ូមតិរបស់យើងដែរ។ យើងត្រូវយល់ទាំងយន្តការថ្នាក់តំបន់ និងយន្តការអន្តរជាតិ ដើម្បីឲ្យយើងអាចដោះស្រាយអនុសាសន៍ទាំងនោះបានប្រសើរ។

លោកមានប្រសាសន៍ថា ក្នុងវដ្តទីមួយ ស.អ.ស.ក មិនមានផែនការដាក់លាក់ណាមួយនោះទេ ហើយក៏មិនមានផែនការដាក់របាយការណ៍រួមដែរ គឺដាក់តែរបាយការណ៍ដាច់ដោយឡែក។ ប៉ុន្តែនៅក្នុងវដ្តទីពីរវិញ ស.អ.ស.ក បានដាក់របាយការណ៍រួម និងបានចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិធ្វើការពាក់ព័ន្ធនឹងសិទ្ធិកុមារ។ ពួកគេក៏បានសហការណ៍ជាមួយអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធផ្សេងៗ ផងដែរ។ លោកថ្លែងថា មុនការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ១៩៩៣ ក្នុងប្រទេសកម្ពុជា និងមុន យូភីអ វដ្តទីមួយ អង្គការមិនមែនរដ្ឋាភិបាល មិនបានចូលរួមសហការ ឬភ្ជាប់បណ្តាញគ្នានោះទេ។ ក៏ប៉ុន្តែ ស.អ.ស.ក បានបញ្ចុះបញ្ចូលឲ្យរដ្ឋា-ភិបាលផ្តល់សច្ចាប័នលើពិធីសារបន្ថែមចំនួនពីរ លើកតិកាសញ្ញាស្តីពីសិទ្ធិកុមារ ដែលរដ្ឋាភិបាលបានផ្តល់សច្ចាប័នក្នុងឆ្នាំ២០០២ និង២០០៤។

លោក មាស សំណាង បានកត់សម្គាល់ថា ប្រសិនបើអនុសាសន៍ជាច្រើនត្រូវបានដោះស្រាយនៅក្នុងវដ្តនេះក៏ដោយ ក៏មិនជានាថានឹងមិនមានអនុសាសន៍ច្រើនទៀតនៅក្នុងវដ្តទីបីនោះដែរ។ ទោះបីជាអនុសាសន៍ទាំងនោះត្រូវបានអនុវត្ត ឬមិនអនុវត្តក្នុងរយៈពេលបួនឆ្នាំខាងមុខ ក៏រដ្ឋាភិបាលនៅតែការពារកំណត់ត្រាសិទ្ធិមនុស្សរបស់ខ្លួនដដែល។ សង្គមស៊ីវិល និងអ្នកជំនាញគួរធ្វើការរួមគ្នា ដោយសារតែពួកគេអាចផ្តល់ការគាំទ្របាន។ លោក មាស សំណាង យល់ឃើញថានេះជាដំណើរការល្អមួយ ហើយប្រសិនបើប្រទេសម្ចាស់ជំនួយអាចបញ្ចុះបញ្ចូលរដ្ឋាភិបាលបានដែរនោះយើងនឹងស្ថិតនៅលើផ្លូវត្រូវហើយ។

*ការឆ្លើយតបដោយលោកស្រីខាធីរីន គួង*

ជាការឆ្លើយតបទៅនឹងសំណួរដែលបានសួរទៅវាគ្មិន លោកស្រីខាធីរីនគួង បានកត់សម្គាល់ថាអង្គការមិនមែនរដ្ឋាភិបាលត្រូវបានផ្តល់ឱកាសឲ្យថ្លែងផ្ទាល់មាត់ ក្នុងអំឡុងសម័យប្រជុំពេញអង្គក្នុងខែមិថុនា របស់ ក.ប.ស។ លោកស្រីបានរំលឹកថា យូភីអ ជាការត្រួតពិនិត្យទៅលើរដ្ឋដោយរដ្ឋ គឺមិនមែនដោយអង្គការសង្គមស៊ីវិលទេ ដូច្នេះភាគច្រើនគឺរដ្ឋជាអ្នកចូលរួមក្នុងដំណើរការ យូភីអ និងផ្តល់អនុសាសន៍ដល់ប្រទេសកម្ពុជា។

ទាក់ទងនឹងសំណួរដែលថាមានប្រទេសផ្សេងៗគ្នាផ្តល់អនុសាសន៍ លោកស្រីគួងបានកត់សម្គាល់ថា អ្វីដែលសំខាន់ យើងមិនត្រូវផ្តោតថាប្រទេសណាជាអ្នកផ្តល់អនុសាសន៍នោះទេ ប៉ុន្តែត្រូវគិតអំពីខ្លឹមសារនៃអនុ សាសន៍នោះទៅវិញ។ សង្គមស៊ីវិលក៏អាចបញ្ចុះបញ្ចូលប្រទេសដែលផ្តល់អនុសាសន៍នោះ ដាក់គំនាបទៅលើប្រទេសកម្ពុជាឲ្យអនុវត្តអនុសាសន៍ទាំងនោះដែរ។ ប្រហែលជាប្រទេសនោះអាចនឹងផ្តល់មូលនិធិ ឬនឹងជួយតាមវិធីផ្សេង។ រដ្ឋដែលផ្តល់អនុសាសន៍ មានដាក់ឈ្មោះប្រទេសខ្លួននៅជាប់នឹងអនុសាសន៍នីមួយៗ។ ទោះបីជាអនុសាសន៍ខ្លះដូចគ្នាក៏ដោយ ក៏រដ្ឋនីមួយៗមានអនុសាសន៍ផ្ទាល់របស់ពួកគេដែរ ដូច្នេះគេអាចមើលឃើញថាតើអនុសាសន៍ណាខ្លះដែលរដ្ឋភាគច្រើនបានផ្តល់ឲ្យ។

លោកស្រីបានបញ្ជាក់ថា យូភីអ គឺជាយន្តការអន្តរជាតិរបស់ អ.ស.ប ។ អ.ស.ប នឹងមិនដាក់ទណ្ឌកម្មណាមួយទៅលើកម្ពុជាសម្រាប់ការមិនអនុវត្តអនុសាសន៍នោះទេ ដោយសារតែ យូភីអ គឺផ្តោតលើកិច្ចសហប្រតិបត្តិការ និងការសន្ទនា។ លោកស្រីបានរំលឹកអ្នកចូលរួមថា ពួកគេគួរចំណាយពេលដើម្បីបញ្ចុះបញ្ចូលរដ្ឋាភិបាលថា ការអនុ-វត្តអនុសាសន៍ទាំងនេះ គឺដើម្បីប្រយោជន៍របស់រដ្ឋាភិបាលផ្ទាល់ទៅវិញទេ។

ទាក់ទងនឹងអនុសញ្ញាស្តីពីសិទ្ធិពលករចំណាកស្រុក លោកស្រី គួង បានថ្លែងថាវាជាការលំបាកណាស់ក្នុងការស្នើឲ្យប្រទេសផ្សេងទៀតផ្តល់សច្ចាប័នអនុសញ្ញានេះ បើកម្ពុជាមិនទាន់បានធ្វើនៅឡើយទេនោះ។ លោកថ្លែងថាប្រទេសកម្ពុជាគួរនាំមុខដោយប្រើឧទាហរណ៍ ហើយនេះនឹងងាយស្រួលក្នុងការបញ្ចុះបញ្ចូលប្រទេសដទៃទៀត។ កម្ពុជាគួរប្តេជ្ញាចិត្តក្នុងការការពារកម្មករចំណាកស្រុកទាំងអស់ មិនមែនត្រឹមតែការពារពលករចំណាក ស្រុកកម្ពុជានោះទេ។

## ៤. “ការបង្កើតផែនការតស៊ូមតិជាយុទ្ធសាស្ត្រក្នុងដំណើរការ យូភីអ”

*បទបង្ហាញដោយលោក ឡាំ សុជាតិ នាយករង វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ*

លោក ឡាំ សុជាតិ ចាប់ផ្តើមបទបង្ហាញដោយបង្ហាញទិដ្ឋភាពទូទៅអំពីជាតុទាំង ៩ នៃផែនការតស៊ូមតិ៖

1. ការបង្កើតគុណតម្លៃ និងចក្ខុវិស័យ, យុទ្ធសាស្ត្រថ្នាក់តំបន់/ថ្នាក់ប្រទេស
2. ការបង្កើតការប៉ាន់ប្រមាណអំពីសមត្ថភាពអង្គភាព និងប្រទេស
3. ការវិភាគបរិបទ និងអំណាច

4. ការកំណត់បញ្ហាសម្រាប់ធ្វើការតស៊ូមតិ
5. ការស្រាវជ្រាវរកភស្តុតាង
6. ការបង្កើតគោលដៅ គោលបំណង សូចនាករ និងលទ្ធផល និងការសរសេរយុទ្ធសាស្ត្រ
7. ការវិភាគភាគីពាក់ព័ន្ធ
8. ការបង្កើតយុទ្ធសាស្ត្រជះឥទ្ធិពល និង
9. ការកំណត់សកម្មភាព និងអន្តរាគមន៍ជាក់លាក់

លោក ឡាំ សុជាតិ ក៏បានបង្ហាញអំពីដំណើរការ យូភីអ ក្នុងប្រទេស ដោយរួមមានបួនដំណាក់កាល ៖ ដំណាក់កាលរៀបចំ ដំណាក់កាលការពារ ដំណាក់កាលអនុវត្ត និងដំណាក់កាលតាមដាន និងវាយតម្លៃ។ លោកបានកត់សម្គាល់ថាអ្នកចូលរួមត្រូវតែរកឲ្យឃើញអំពីរបៀបធ្វើការតស៊ូមតិក្នុងដំណាក់កាលនីមួយៗ ត្រូវរកឲ្យឃើញនូវចំណុចចូល និងបង្កើតយុទ្ធសាស្ត្រតស៊ូមតិសម្រាប់ដំណាក់កាលនីមួយៗ។

លោកបានផ្តល់ដល់អ្នកចូលរួមអំពីយុទ្ធសាស្ត្រ និងសកម្មភាពតស៊ូមតិទូទៅ ដែលរួមមាន ៖

1. ការកសាងទំនាក់ទំនងជាមួយមន្ត្រី និងអ្នកតំណាងរដ្ឋាភិបាល
2. ការធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ
3. ការបង្កើត និងរក្សាសម្ព័ន្ធភាព
4. ការតស៊ូមតិតាមរយៈដំណើរការខាងផ្នែកច្បាប់ និង
5. ការគៀងគរកម្លាំងតាមមូលដ្ឋាន

មានការលើកឡើងថាសកម្មភាពតស៊ូមតិ ជាការបញ្ចុះបញ្ចូលដែលផ្តោតលើគោលនយោបាយ, ជាការស្រាវ-ជ្រាវ និងសរសេររបាយការណ៍ និងការបោះពុម្ពផ្សាយ, ការធ្វើយុទ្ធនាការ និងសកម្មភាពលើកកម្ពស់ការយល់ដឹង, ការងារប្រព័ន្ធផ្សព្វផ្សាយ, ការកសាងសមត្ថភាពអ្នកពង្រឹងការអនុវត្តច្បាប់, ការតាមដានត្រួតពិនិត្យទៅលើការអនុវត្តគោលនយោបាយ, វិធានការផ្លូវច្បាប់ និងការចែករំលែកព័ត៌មាន។ លោក ឡាំ សុជាតិ បានលើកឡើងថា នៅពេលយើងបង្កើតសកម្មភាពតស៊ូមតិ យើងត្រូវកំណត់ថាតើវាមានលក្ខណៈ "ទន់" ឬ "រឹង"។ ទន់ មានន័យថា ជាការមិនសូវប្រឈមមុខនឹងគោលដៅ។ រឹងមានន័យថា ជាការមានបញ្ហាប្រឈមមុខខ្លាំងជាមួយនឹងគោលដៅ។ សម្រាប់ដំណាក់កាលតាមដានបន្ត និងអនុវត្តនៃដំណើរការ យូភីអ សង្គមស៊ីវិលគួរផ្សព្វផ្សាយអនុសាសន៍ យូភីអ រក្សាការសន្ទនារវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ការអនុវត្ត និងតាមដានការវិវឌ្ឍន៍ក្នុងការអនុវត្ត។

### *សំណួរ*

អ្នកចូលរួមលើកឡើងនូវសំណួរជាច្រើនដូចខាងក្រោម ៖

- លោកលើកឡើងថា ក្នុងគោលបំណងដើម្បីបង្កើតយុទ្ធសាស្ត្រតស៊ូមតិឲ្យមានប្រសិទ្ធភាព យើងត្រូវស្នើឲ្យមានការផ្លាស់ប្តូរទៅដល់រដ្ឋាភិបាល។ តើយើងធ្វើដូចម្តេចទើបដឹងថាយើងស្ថិតនៅក្នុងដំណាក់កាលណា? តើយើងធ្វើដូចម្តេចដើម្បីឲ្យដឹងថាតើរដ្ឋាភិបាលស្ថិតនៅក្នុងដំណាក់កាលណា?
- ប្រសិនបើយើងធ្វើការតស៊ូមតិអំពីការបោះឆ្នោត តើយើងធ្វើដូចម្តេចដើម្បីបង្ហាញថាការតស៊ូមតិនេះមិនមែនចេញមកត្រឹមតែពីអង្គការមិនមែនរដ្ឋាភិបាលទេ គឺក៏ចេញមកពីប្រជាជនដែរនោះ?
- ខ្ញុំចង់សួរបន្តិចអំពីសម្ព័ន្ធភាព ភាពអព្យាក្រឹត្យ និងគូបដិបក្ខ។ តើយើងធ្វើដូចម្តេចដើម្បីអូសទាញឲ្យគូបដិបក្ខចូលរួមជាមួយយើង ឬបញ្ឈប់ពួកគេកុំឲ្យជ្រៀតជ្រែកការងាររបស់យើង?
- ខ្ញុំចង់សួរអំពីសូចនាករសម្រាប់រយៈពេលបួនឆ្នាំខាងមុខ។ តើគួរមានលក្ខណៈជាគុណភាព ឬបរិមាណក្នុងគ្រប់វិស័យទាំងអស់? ហើយតើយើងអាចវាស់ស្ទង់សូចនាករទាំងអស់នោះយ៉ាងដូចម្តេច?

### *ការឆ្លើយតបដោយលោក ឡាំ សុជាតិ*

ទាក់ទងនឹងការកំណត់ថាតើរដ្ឋាភិបាលស្ថិតក្នុងដំណាក់កាលណាមួយនោះ លោក ឡាំ សុជាតិ បានឆ្លើយថា មិនមែនជាការលំបាកក្នុងការទទួលបានព័ត៌មាននោះទេ ដោយសារតែមាននៅក្នុងរបៀបវារៈ និងព្រឹត្តិការណ៍សំខាន់ៗ ដែលផ្សព្វផ្សាយនៅក្នុងព័ត៌មាន ហើយជាងនេះទៀត កាលវិភាគរបស់ អ.ស.ប មានដាក់ជាសាធារណៈដូច្នេះមិនពិបាករកនោះទេ។

ទាក់ទងនឹងតំណាង លោកមានប្រសាសន៍ថា ជាការសំខាន់ ហើយត្រូវមានការយល់ព្រមពីប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដើម្បីឲ្យមើលឃើញថាជាតំណាងស្របច្បាប់របស់ប្រជាជន។ ឧទាហរណ៍ គេអាចធ្វើបានតាមរយៈការស្ទង់មតិអង្កេតបឋមជាដើម។

ឆ្លើយតបនឹងសំណួរអំពីសម្ព័ន្ធមិត្ត អព្យាក្រឹត្យ និងគូបដិបក្ខ, លោក ឡាំ សុជាតិ ឆ្លើយថា យើងគួរតែវិភាគតួអង្គទាំងបីនេះ។ សម្រាប់គូបដិបក្ខ យើងគួរឲ្យពួកគេចូលរួមដើម្បីឲ្យពួកគេក្លាយទៅជាអ្នកគាំទ្រ ដោយចាប់ផ្តើមតាមរយៈការវិភាគ ថាតើទស្សនៈរបស់ពួកគេមានការគាំទ្រប្រកបដោយប្រជាប្រិយភាពឬទេ ហើយថាតើហេតុអ្វីបានជាពួកគេមិនគាំទ្រជំហររបស់អង្គការនោះ។ បន្ទាប់មក គួរផ្តោតលើរបៀបវារៈ និងអាទិភាពរបស់ពួកគេ ហើយថាតើហេតុអ្វីបានជាពួកគេមានទស្សនៈបែបនោះ។

ទាក់ទងនឹងសូចនាករ លោកលើកឡើងថាសូចនាករអំពីភាពជោគជ័យ ត្រូវមានទាំងលក្ខណៈគុណភាព និងបរិមាណ ហើយសូចនាករដែលត្រូវបានជ្រើសរើសនោះ គួរត្រូវផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវ។

សរុបមក លោកកត់សម្គាល់ថាក្នុងការធ្វើការតស៊ូមតិ យើងត្រូវមានការគិតបែបវិជ្ជមាន។ ការគិតបែបអវិជ្ជមាន និងការរិះគន់មិនជួយដល់ចលនាតស៊ូមតិទេ។ មានរឿងអាក្រក់ និងមានរឿងល្អមួយចំនួន ប៉ុន្តែលោកបានលើកទឹកចិត្តឲ្យអ្នកចូលរួមមានភាពវិជ្ជមាន និងត្រូវជឿថាពួកគេនឹងអាចទទួលបានជោគជ័យនៅថ្ងៃណាមួយ។ លោកលើកឡើងថា ប្រសិនបើលោកមហាត្មះ គន្ទី និងលោកមែនដឺឡា អាចរស់នៅក្នុងពន្ធនាគារអស់មួយភាគបីនៃជីវិតរបស់ពួកលោកនោះ យើងនៅតែអាចមានសង្ឃឹម។

## ៥. "ដំណើរការ យូភីអរ"

*បទបង្ហាញដោយ លោកស្រី ហ្វ្រង់ហ្សេស្កា ពីហ្ស៊ីន, អ្នកគ្រប់គ្រងកម្មវិធី, ព័ត៌មាន យូភីអ អ៊ីនហ្វូ*

លោកស្រី ហ្វ្រង់ហ្សេស្កា ពីហ្ស៊ីន ចាប់ផ្ដើមដោយកត់សម្គាល់ថា ការពិគ្រោះយោបល់នេះគឺជាសកម្មភាពតាមដានមួយដែលត្រូវការការចូលរួមពីសង្គមស៊ីវិលបន្ទាប់ពី យូភីអ និងបានអរគុណដល់អ្នករៀបចំកម្មវិធី។ លោកស្រីពន្យល់ថា យូភីអ អ៊ីនហ្វូ ព្យាយាមគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលធ្វើការលើវិស័យសិទ្ធិមនុស្ស និងធ្វើឲ្យយន្តការសិទ្ធិមនុស្សមាននិរន្តរភាព និងកាន់តែមានប្រសិទ្ធភាពក្នុងការអនុវត្តជាក់ស្ដែង។ អង្គការនេះប្ដេជ្ញាចិត្តក្នុងការពង្រឹងចំណេះដឹងអំពីដំណើរការ យូភីអ ជុំវិញពិភពលោក អង្គការនេះមិនធ្វើការតស៊ូមតិទេ ប៉ុន្តែគាំទ្រជាខ្លាំងដល់អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល និងជួយឲ្យភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីអាចប្រើប្រាស់ដំណើរការនេះបានផងដែរ។ លោកស្រីបានកត់សម្គាល់ថា ប្រការសំខាន់បំផុតនោះគឺ ឲ្យប្រជាជនចូលរួមដោយផ្ទាល់ជាមួយស្ថាប័នសិទ្ធិមនុស្ស។

លោកស្រីពន្យល់ថា យូភីអ អ៊ីនហ្វូ មានទំព័រមួយអំពីប្រទេសកម្ពុជា ដែលយើងអាចរកបានព័ត៌មានទាំងអស់អំពីវដ្ត យូភីអ របស់ប្រទេសកម្ពុជានៅលើទំព័រនោះ។ យើងអាចរកបានរាល់ឯកសារផ្លូវការទាំងអស់របស់ អ.ស.ប រួមទាំងរបាយការណ៍ដែលដែលសង្គមស៊ីវិលបានដាក់ទៅផងដែរ។ យូភីអ អ៊ីនហ្វូ បានកត់ត្រារាល់ព័ត៌មានដែលកម្ពុជាបានទទួល និង ផ្ដល់ឲ្យនៅក្នុងគ្រប់វដ្ត យូភីអ ទាំងអស់។

លោកស្រី ពីហ្ស៊ីន បានថ្លែងថា ពេលនេះជាពេលដែលអង្គការសង្គមស៊ីវិលត្រូវដើរជាតួអង្គមួយនៅក្នុងដំណើរការនេះ។ រឿងមួយដែលជាបញ្ហាប្រឈមនោះ គឺការតាមដានថាតើប្រទេសមួយទទួលបានអនុសាសន៍ច្រើនដែរឬទេ ហើយប្រទេសកម្ពុជាបានទទួលអនុសាសន៍ជាច្រើន។ លោកស្រីបានពន្យល់ថា ក្នុងអំឡុងវដ្តដំបូង ចំនួនអនុសាសន៍ជាមធ្យមប្រហែលជា ១១០ ខណៈពេលដែលក្នុងអំឡុងវដ្តទីពីរ ចំនួនជាមធ្យមប្រហែល ២៦០ ដូច្នេះ នេះជានិន្នាការមួយដែលប្រទេសជាច្រើនទទួលបានអនុសាសន៍កាន់តែច្រើន ពេលដែលដំណើរនេះមានភាពចាស់ទុំ។

យោងតាមលោកស្រី ពីហ្ស៊ីន យូភីអ គឺជាយន្តការមួយដែលតែងតែមានការប្រែប្រួល គឺជាយន្តការដែលកំពុងធ្វើការសាជាថ្មីម្ដងទៀត។ ឥឡូវនេះ រដ្ឋ និងរដ្ឋាភិបាលបានយល់កាន់តែច្រើន ពីរបៀបដែលយន្តការ យូភីអ ប្រតិបត្តិការ ដូច្នេះគឺមានភាពងាយស្រួលក្នុងការធ្វើការជុំវិញរឿងនេះ។ លោកស្រីបានលើកឡើងថា មានតួអង្គកាន់តែច្រើន

បានចូលរួមក្នុងដំណើរការនេះ ដូច្នេះហើយបានជាមានអនុសាសន៍ជាច្រើនត្រូវបានលើកឡើង។ ប៉ុន្តែ តាមទស្សនៈរបស់លោកស្រី ចំនួនមិនសំខាន់ទេ។ ក្នុងចំណោមអនុសាសន៍ទាំងអស់ ប្រទេសកម្ពុជាទទួលយកជិត ១៧០ និងកត់សម្គាល់អនុសាសន៍ផ្សេងទៀតដែលនៅសល់។ គេមិនអាចបដិសេធអនុសាសន៍ណាបានទេ ពីព្រោះទោះបីជាប្រទេសមួយមិនអាចទទួលយកអនុសាសន៍បានក៏ដោយ ក៏មិនមែនមានន័យពួកគេមិនគួរធ្វើការដោះស្រាយទៅលើអនុសាសន៍ទាំងនោះដែរ។ អនុសាសន៍ភាគច្រើនដែលកម្ពុជាបាន "កត់សម្គាល់" មានការជាប់ទាក់ទងនឹងសន្ធិសញ្ញា និងនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ។ ក៏ប៉ុន្តែ នេះមិនមែនមានន័យថាសង្គមស៊ីវិលមិនអាចធ្វើការឲ្យប្រទេសកម្ពុជាអនុម័តនោះទេ។

លោកស្រី ពីហ្ស៊ីន បានចែករំលែកការអនុវត្តល្អបំផុតមួយចំនួនទាក់ទងនឹង យូភីអ។ នៅប៉ាគីស្ថាន មួយខែក្រោយពីការត្រួតពិនិត្យ រដ្ឋាភិបាលបានអនុម័តច្បាប់មួយទាក់ទងនឹងភាពចាំបាច់នៃការអប់រំ។ ប្រទេសនេះមិនដែលបានគិតអំពីបញ្ហាទាំងនេះមុនពេលមានដំណើរការ យូភីអ នេះទេ ប៉ុន្តែដោយសារតែការងាររបស់សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការរួមគ្នានោះ ធ្វើឲ្យពួកគេទទួលបានលទ្ធផលដ៏ល្អប្រសើរ។ ឧទាហរណ៍មួយទៀតអំពីបង់ក្លាដេស។ អង្គការមិនមែនរដ្ឋាភិបាលធ្វើការទាក់ទងនឹងសិទ្ធិកុមារបានតស៊ូមតិនៅបង់ក្លាដេស និងបានធ្វើឲ្យសិទ្ធិកុមារនៅក្នុងច្បាប់មានភាពប្រសើរឡើង។ ជាចុងក្រោយ ក្នុងប្រទេសកុងហ្គូ-ប្រាហ្សាវីល អង្គការមិនមែនរដ្ឋាភិបាលបី ដែលមិនដែលធ្លាប់ស្គាល់គ្នាពីមុនមកនោះ បានធ្វើការតាមដាន យូភីអ នេះ។ ពួកគេសម្រេចចូលរួមជាមួយគ្នាហើយបង្កើតបានជាសម្ព័ន្ធមួយដើម្បីធ្វើការទៅលើការអនុវត្តអនុសាសន៍ទាំងនោះ។

លោកស្រី ពីហ្ស៊ីន ផ្តល់អនុសាសន៍ឲ្យអ្នកចូលរួមទាំងឡាយធ្វើការជាមួយអង្គការផ្សេងៗ នៅកម្ពុជាផងដែរ ដោយផ្តោតទៅលើអនុសាសន៍មួយចំនួនតូចដែលត្រូវនឹងជំនាញរបស់ខ្លួន និងចូលរួមជាមួយអង្គការ និងនាយកដ្ឋានរដ្ឋាភិបាលដែលមានការជាប់ពាក់ព័ន្ធ ស្ថាប័នសិទ្ធិមនុស្សជាតិ សមាជិកសភា និងអ្នកផ្សេងទៀត។ លោកស្រីក៏បានផ្តល់អនុសាសន៍ផងដែរថាអង្គការគួរព្យាយាមសហការជាមួយប្រព័ន្ធផ្សព្វផ្សាយ ដោយសារតែពួកគេគឺជាតួអង្គសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មាន។

លោកស្រី បានសង្កត់ធ្ងន់ថា សំណើទាំងនេះមានភាពទូទៅខ្លាំង ហើយអង្គការនីមួយៗត្រូវសម្រេចចិត្តថាតើពួកគេចង់ធ្វើអ្វី និងត្រូវធ្វើយ៉ាងដូចម្តេច។ ប្រការសំខាន់គឺការលើកកម្ពស់ការយល់ដឹងនៅក្នុងសង្គម។ លោកស្រីបានកត់សម្គាល់ថា បញ្ហាប្រឈមធំមួយគឺថា អ្វីដែលកើតឡើងក្នុងទីក្រុងហ្សឺណែវ ហើយស្ថិតនៅក្រុងហ្សឺណែវ ដូច្នេះ អ្វីដែលកើតឡើងក្នុងប្រទេសកម្ពុជា គេមិនដឹងទេ។ លោកស្រីបានស្នើថា អ្នកចូលរួមគួរព្យាយាមធ្វើការជាមួយតួអង្គផ្សេងៗនៅក្នុងប្រទេស និងធ្វើឲ្យមនុស្សទាំងអស់ក្នុងប្រទេសទទួលបានអនុសាសន៍ទាំងអស់នោះ ដូចជាតាមរយៈការបកប្រែឯកសារទៅជាភាសាដែលប្រើក្នុងប្រទេសកម្ពុជា និងធ្វើការជាមួយសមាជិកសហគមន៍មកពីទូទាំងប្រទេស។ លោកស្រីក៏បានស្នើទៅអ្នកចូលរួម ថាគួរចូលរួមជាមួយស្ថានទូតដែលមានទីតាំងនៅកម្ពុជា ដោយទាញ

យកប្រយោជន៍ពីរដ្ឋដែលបានផ្តល់អនុសាសន៍ និងដាក់សម្ពាធទៅលើរដ្ឋាភិបាលនៃរដ្ឋដែលបានផ្តល់អនុសាសន៍ឲ្យជួយខ្លួនក្នុងកិច្ចខំប្រឹងប្រែងក្នុងការតាមដាន។

### *សំណួរ*

- សម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលមិនធ្លាប់បានជួបគ្នា និងមិនបានបង្កើតសម្ព័ន្ធភាពរួមគ្នានៅឡើយទេនោះ យើងដឹងថាការអនុវត្តគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ចុះហេតុអ្វីបានជាអង្គការមិនមែនរដ្ឋាភិបាលខិតខំប្រឹងធ្វើការខ្លាំងម្លេះ បើទំនួលខុសត្រូវក្នុងការអនុវត្តគឺជាបន្ទុករបស់រដ្ឋនោះ?
- អនុសាសន៍ទាំងនោះ មិនមានការចងកាតព្វកិច្ចផ្លូវច្បាប់ទេ ដូច្នេះ ប្រសិនបើរដ្ឋមិនអនុវត្តអនុសាសន៍ទាំងនោះទេ តើគេធ្វើអ្វីបន្តទៀត?
- តើសង្គមស៊ីវិលត្រូវមានយុទ្ធសាស្ត្រអ្វីខ្លះ ដែលអាចផ្តល់ទៅឲ្យរដ្ឋាភិបាលដើម្បីធានាថារដ្ឋាភិបាលទទួលយក និងអនុវត្តអនុសាសន៍របស់ពួកយើង។
- ប្រព័ន្ធផ្សព្វផ្សាយមានផលប៉ះពាល់ច្រើន ប៉ុន្តែក្នុងប្រទេសកម្ពុជា ប្រព័ន្ធផ្សព្វផ្សាយភាគច្រើននៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល ដូច្នេះ តើយើងអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយយ៉ាងដូចម្តេចដើម្បីដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាលដោយរបៀបណា ពេលដែលស្ថាប័នប្រព័ន្ធផ្សព្វផ្សាយភាគច្រើនស្ថិតក្រោមការត្រួតត្រារបស់រដ្ឋាភិបាលនោះ?

### *ការឆ្លើយតបដោយលោកស្រី ពីហ្វ៊ីន*

លោកស្រី ពីហ្វ៊ីន កត់សម្គាល់ថា យូភូអ មិនមែនជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលក្នុងការអនុវត្តអនុសាសន៍ទាំងនោះទេ ក៏ប៉ុន្តែជាការទទួលខុសត្រូវរបស់សង្គម។ អនុសាសន៍ទាំងនោះមិនមានឥទ្ធិពលលើរដ្ឋាភិ-បាលទេ តែមានឥទ្ធិពលទៅលើប្រជាពលរដ្ឋ ជាពិសេសសម្រាប់អ្នកដែលត្រូវការអនុសាសន៍ទាំងនោះ។ ប្រសិនបើមិនមានការជំរុញពីសង្គមស៊ីវិលឲ្យទទួលយកអនុសាសន៍ទេនោះ រដ្ឋាភិបាលនឹងធ្វើការតែទៅលើអនុសាសន៍ដែលពួកគេចូលចិត្ត និងងាយស្រួលក្នុងការអនុវត្តតែប៉ុណ្ណោះ។ ចុះចំណែកអនុសាសន៍ផ្សេងទៀតយ៉ាងម៉េចដែរ? ចុះចំណែកអនុសាសន៍ដែលពិបាកអនុវត្ត ឬសំខាន់ក្នុងការអនុវត្ត? នឹងមិនមាននរណាម្នាក់ធ្វើការលើបញ្ហាសំខាន់ និងក្តៅគគុកទាំងនោះទេ ប្រសិនបើសង្គមស៊ីវិលមិនធ្វើ។ តាមទស្សនៈរបស់លោកស្រី សង្គមស៊ីវិលគឺជាតួអង្គសំខាន់បំផុតក្នុងការអនុវត្ត។

លោកស្រីក៏បានលើកឡើងដែរថា ទោះបីជាអនុសាសន៍ទាំងនោះមិនចងកាតព្វកិច្ចខាងផ្លូវច្បាប់ក៏ដោយ ក៏យូភីអ ជាយន្តការ អ.ស.ប តែមួយគត់ក្នុងការដោះស្រាយជាមួយរដ្ឋជាសមាជិកទាំងអស់។ សម្រាប់ស្ថាប័នសន្ធិ-សញ្ញា និងកតិកាសញ្ញាដទៃទៀត ប្រទេសទាំងឡាយត្រូវផ្តល់សច្ចាប័ន និងចុះហត្ថលេខា។ ដូច្នេះទោះបីជា យូភីអ ជាយន្តការមិនមានចងកាតព្វកិច្ចក៏ដោយ ក៏មិនមានរដ្ឋណាចង់ខូចកិត្តិយសនៅចំពោះសហគមន៍អន្តរជាតិឡើយ។

ដូច្នេះ ការគាបសង្កត់លើរដ្ឋាភិបាល និងការធ្វើការជាមួយស្ថានទូតទៅលើការអនុវត្តនៅថ្នាក់មូលដ្ឋាន ជាប្រការសំខាន់ខ្លាំងណាស់។

លោកស្រី ពីហ្សឺន ពន្យល់ថាពួកគេអាចមើលឃើញថាដំណើរការនេះកំពុងតែដំណើរការទៅហើយ! ជាមធ្យមអនុសាសន៍ប្រមាណជា ៤៥% ដែលបានធ្វើឡើងក្នុងវដ្តទីមួយ បានផ្តល់ទៅឲ្យរដ្ឋជាសមាជិករបស់ អ.ស.ប ត្រូវបានអនុវត្តខ្លះ។ រដ្ឋនីមួយៗនឹងត្រូវពិនិត្យឡើងវិញ និងចង់មានមុខមាត់ល្អ ដូច្នេះ ច្បាស់ណាស់ថារដ្ឋាភិបាលត្រូវធ្វើយ៉ាងណាសំដៅធ្វើឲ្យកំណត់ត្រាសិទ្ធិមនុស្សមានសភាពល្អប្រសើរ។ ទោះបីជាមិនមានចងកាតព្វកិច្ចផ្លូវច្បាប់ក៏ដោយ ក៏នេះនៅតែជាអ្វីមួយនៅក្នុងកំណត់ត្រាដែលនឹងត្រូវគេយកមកពិភាក្សានៅក្នុងកម្រិតអន្តរជាតិ ក្នុងវេទិកាអន្តរជាតិជាមិនខាន។ លោកស្រីកត់សម្គាល់ថា តួអង្គអន្តរជាតិនឹងស្តាប់នូវអ្វីដែលកំពុងកើតឡើង ដោយពិនិត្យមើលលើអនុ-សាសន៍ទាំងឡាយដែលរដ្ឋទទួលយក។ គំនាបសង្កត់ពីរដ្ឋាភិបាលផ្សេងទៀត ជាឧបករណ៍ដ៏សំខាន់មួយ ហើយលោកស្រី ពីហ្សឺន ជំរុញឲ្យអ្នកចូលរួមសហការណ៍ជាមួយតួអង្គផ្សេងទៀតក្នុងដំណើរការនេះ។

ពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ លោកស្រីបានថ្លែងថាយុទ្ធសាស្ត្រត្រូវអាស្រ័យទៅលើស្ថានភាពនៃប្រទេស។ តែជាអកុសល លើកលែងតែរដ្ឋាភិបាលចាត់វិធានការខ្លះដើម្បីការពារសេរីភាពបញ្ចេញមតិ បើមិនដូច្នោះទេ នឹងជាបញ្ហាប្រឈមខ្លាំងមួយ។ ក៏ប៉ុន្តែ លោកស្រីបញ្ជាក់ថា ប្រព័ន្ធផ្សព្វផ្សាយមិនមែនមានត្រឹមតែសារព័ត៌មានទេ ក៏រួមមានទាំងប្លុក ប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលជា "ប្រព័ន្ធផ្សព្វផ្សាយថ្មីមួយ" ផងដែរ។ ប្រព័ន្ធផ្សព្វផ្សាយប្រពៃណី នឹងនៅតែមានវត្តមានជានិច្ចហើយនឹងនៅតែត្រូវបានបន្តប្រើប្រាស់ ក៏ប៉ុន្តែ ប្រព័ន្ធផ្សព្វផ្សាយថ្មីក៏សំខាន់ដែរ។ លោកស្រីបានជំរុញឲ្យអ្នកចូលរួម ធានាថាពួកគេមានប្រកដទៃផ្សេងទៀតទាក់ទងនឹងព័ត៌មាន។

លោកស្រី ពីហ្សឺន ថ្លែងបញ្ចប់ដោយកត់សម្គាល់ថា យូភីអ ជាយន្តការដ៏មានតម្លាភាពជាខ្លាំង និងថាការដែលសង្គមស៊ីវិលកំពុងធ្វើការជាមួយរដ្ឋាភិបាល និងផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលបាននោះ គឺជាសមិទ្ធិផលដ៏ធំមួយរួចទៅហើយ។ ការធ្វើការជាមួយរដ្ឋាភិបាលមិនតែងតែមានភាពងាយស្រួលនោះទេ ដូច្នេះជាការសំខាន់ណាស់ក្នុងការធានាថាព័ត៌មានដែលសង្គមស៊ីវិលមាន អាចឲ្យគេរកបាន ហើយថាអ្នកចូលរួមត្រូវទាញយកប្រយោជន៍ពីព័ត៌មានទាំងនោះឲ្យបាន។ លោកស្រីបានស្នើឡើងថា អ្នកចូលរួមគួរចាប់ផ្តើមធ្វើការទៅលើអនុសាសន៍ ដែលអាចងាយចូលទៅកាន់ និងដែលមានភាពងាយស្រួលសម្រាប់រដ្ឋាភិបាលទទួលយក ហើយបន្ថែមថាពួកគេមិនគួរចាប់ផ្តើមជាមួយនឹងអនុសាសន៍ដែលលំបាកបំផុតនោះទេ។ ឧទាហរណ៍ លោកស្រីស្នើឡើងថា អាចមានភាពសមហេតុផលខ្លះដោយការចាប់ផ្តើមជាមួយអនុសាសន៍ពាក់ព័ន្ធនឹងស្ត្រីនិងកុមារ ដែលអាចងាយស្រួលសម្រាប់រដ្ឋាភិបាលក្នុងការទទួលយក។ លោកស្រីជំរុញឲ្យអ្នកចូលរួមព្យាយាមឲ្យបានខ្លាំងក្នុងការសហការណ៍ជាមួយរដ្ឋាភិបាល និងធ្វើការជាមួយស្ថានទូតនៃរដ្ឋដែលផ្តល់អនុសាសន៍។ រដ្ឋាភិបាលអាចនឹងមានឆន្ទៈក្នុងការទទួលយកសំណើពីរដ្ឋផ្សេងទៀតច្រើនជាងឆន្ទៈក្នុងការទទួលពីសង្គមស៊ីវិល។

# ការពិភាក្សាជាក្រុម និង អនុសាសន៍

ក្នុងរយៈពេល នៃការពិគ្រោះយោបល់ចំនួនពីរថ្ងៃនេះ យើងក៏មានបែងចេកជាក្រុមពិភាក្សាពីរវគ្គ ដើម្បីឲ្យអ្នកចូលរួមពិភាក្សាស៊ីជម្រៅ ទៅលើអនុសាសន៍ដែលពាក់ព័ន្ធនឹងការងារសំខាន់ៗ របស់អង្គការ ដោយផ្តោតទៅលើតើអនុសាសន៍ណា គួរចាត់ជាអាទិភាពរយៈពេលខ្លី មធ្យម និងវែង ហើយបំផុសគំនិតពីយុទ្ធសាស្ត្រ និងគោលដៅសម្រាប់ធ្វើការតស៊ូមតិទៅលើការអនុវត្តអនុសាសន៍ទាំងអស់នោះ។ អ្នកចូលរួមត្រូវបានបែងចែកជាប្រាំក្រុមតូចៗ ដែលរួមមាន (១) សេរីភាពខាងការបញ្ចេញមតិ, (២) កំណែទម្រង់តុលាការ, (៣) សិទ្ធិដីធ្លី, (៤) សិទ្ធិស្ត្រី និងកុមារ, (៥) សិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌។ ផ្នែកខាងក្រោម គឺជាការសង្ខេបអំពីលទ្ធផលដែលទទួលបានពីការពិភាក្សាតាមក្រុមសម្រាប់ក្រុមនីមួយៗតាមប្រធានបទ[3]។



## *សេរីភាពខាងការបញ្ចេញមតិ*

តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតទៅលើសេរីភាពខាងការបញ្ចេញមតិ កំណត់យក **អនុសាសន៍ ១១៨.១៧, ១១៨.១៨ និង ១១៨.២០**[4] ជាអាទិភាពសម្រាប់អនុវត្ត និងតស៊ូមតិ។ គោលបំណងរបស់ក្រុមនេះ គឺពង្រឹង និងការពារសេរីភាពខាងការបញ្ចេញមតិ និងធ្វើឲ្យសិទ្ធិរបស់បុគ្គលគ្រប់រូបមានការប្រសើរឡើង ជាពិសេសតាមរយៈការប្រើប្រាស់អ្នកជំនួញ និងអ្នកនយោបាយ។ ក្រុមនេះ កត់សម្គាល់ឃើញអំពីតម្រូវការក្នុងការចូលរួមយ៉ាងសកម្ម និងតាមដានឲ្យបានដិតស្និទ្ធទៅលើសកម្មភាពរបស់រដ្ឋាភិបាលទាក់ទងនឹងការអនុវត្តអនុសាសន៍ និងដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុនិងបច្ចេកទេស ប្រសិនបើចាំបាច់។ អ្នកចូលរួមបានសង្កត់ធ្ងន់អំពីតម្រូវការធ្វើការសហការណ៍ជាមួយរដ្ឋាភិបាល ជាជាងគ្រាន់តែរិះគន់ ដើម្បីពិនិត្យទៅលើសូចនាករដែលរៀបចំដោយរដ្ឋាភិបាល និងដើម្បីផ្តល់របាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតទៅរដ្ឋាភិបាល។

---

[3] ទស្សនៈ និងអនុសាសន៍ដែលបានបង្ហាញដោយអ្នកចូលរួមមិនឆ្លុះបញ្ចាំងអំពីជំហរ និងអនុសាសន៍របស់ ម.ស.ម.ក ទៅដល់រដ្ឋាភិបាលទេ

[4] សូមមើលឧបសម្ព័ន្ធទី១សម្រាប់អនុសាសន៍ពេញ

ក្រុមនេះសម្រេចចិត្តផ្តោតទៅលើវិស័យការងារចំនួនបី៖ (១) ជំរុញឲ្យរដ្ឋាភិបាលអនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មានមុន ឆ្នាំ២០១៥, (២) លើកទឹកចិត្តឲ្យរដ្ឋាភិបាលដើម្បីបង្កើតឧបករណ៍ច្រើនថែមទៀត ដើម្បីឲ្យសាធារណជនទទួលព័ត៌មាន, និង (៣) ពិនិត្យឡើងវិញទៅលើក្រមព្រហ្មទណ្ឌស្តីពីគ្រប់ចំណុចដែលទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិ និងមើលថាតើចំណុចទាំងនេះស្របនឹងស្តង់ដារអន្តរជាតិដែរឬទេ។ ភាគីពាក់ព័ន្ធដែលត្រូវបានកំណត់ដោយក្រុមនេះរួមមាន អ្នកសារព័ត៌មាន ម្ចាស់ជំនួយ ប្រជាពលរដ្ឋ សហជីព ស្ថានទូត គណបក្សនយោបាយ អង្គការសហប្រជាជាតិ បណ្តាញអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកផ្សេងទៀត។

ពួកគេក៏បានបង្ហាញអំពីយុទ្ធសាស្ត្រតស៊ូមតិដែលមានចំនួនបី៖ (១) ធ្វើការជាមួយរដ្ឋាភិបាលដោយបង្កើតទំនាក់ទំនងជាមួយរដ្ឋាភិបាល ដើម្បីឲ្យអង្គការមិនមែនរដ្ឋាភិបាលអាចដឹងទាន់ពេលវេលាអំពីអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ, (២) ធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ, និង (៣) គៀងគរសហគមន៍ ដោយរាប់បញ្ចូលទាំងការបង្កើនចំណេះដឹង និងការយល់ដឹងអំពីសិទ្ធិរបស់ពួកគេ។ សកម្មភាពតស៊ូមតិជាក់លាក់ ដែលក្រុមនេះបានរកឃើញ រួមមានការធ្វើការស្រាវជ្រាវផ្នែកគោលនយោបាយ, ការបញ្ចុះបញ្ចូលប្រព័ន្ធផ្សព្វផ្សាយ, ការរៀបចំកិច្ចប្រជុំចរចា, ការរៀបចំសិក្ខាសាលា និងការរៀបចំវគ្គបណ្តុះបណ្តាល។

## *កំណែទម្រង់តុលាការ*

តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតលើកំណែទម្រង់តុលាការ កំណត់ **អនុសាសន៍១១៩.១៩ និង ១១៨.២៣** ជាអាទិភាពសម្រាប់អនុវត្ត និងតស៊ូមតិ។ ការធ្វើបទបង្ហាញរបស់ក្រុមផ្តោតលើថាតើក្រុមខ្លួនអាចជួយអ្វីខ្លះដល់រដ្ឋាភិបាលក្នុងការអនុវត្តអនុសាសន៍ និងអាចធ្វើការសហការណ៍ជាមួយអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតបានយ៉ាងដូចម្តេចខ្លះ។ គំនិតមួយក្នុងចំណោមគំនិតជាច្រើនដែលបានលើកឡើង គឺការបង្កើតក្រុមការងារផ្តោតលើកំណែទម្រង់តុលាការ ដែលអាចផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋាភិបាល ចែករំលែកចំណេះដឹងជាមួយអ្នកផ្សេងទៀត តាមរយៈការផ្តល់បទបង្ហាញស្តីពីការអនុវត្តមិនប្រក្រតី និងមិនយុត្តិធម៌ក្នុងតុលាការ រៀបចំសន្និសីទសារព័ត៌មានដើម្បីផ្តល់ដំណឹងដល់សាធារណជន រៀបចំ និងដាក់របាយការណ៍ស្រមោលទាក់ទងនឹងកំណែទម្រង់តុលាការ និងបង្កើតនីតិវិធីតាមដានត្រួតពិនិត្យ។

ភាគីពាក់ព័ន្ធដែលមានក្នុងក្រុមនេះ រួមមាន មន្ត្រីរដ្ឋាភិបាលមកពីក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាជិករដ្ឋសភា សមាជិកគណបក្សនយោបាយ ជាពិសេស គណបក្សសង្គ្រោះជាតិកម្ពុជា («គ.ស.ជ») និងគណបក្សប្រជាជនកម្ពុជា («ប្រ.ជ») សង្គមស៊ីវិល សកម្មជនសហគមន៍ និងអង្គការអន្តរជាតិ។ ក្រុមនេះក៏បញ្ជាក់អំពីបំណងប្រាថ្នាក្នុងការសហការណ៍ជាមួយភ្នាក់ងារដូចជា យូអិនឌីភី សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលដូចជាអង្គការលីកាដូ និងខុមហ្វ្រែល និងភ្នាក់ងារដទៃទៀត។ អាទិភាពសម្រាប់ធ្វើសកម្មភាពដែលក្រុមបានរកឃើញ រួមមាន ការកសាង និងការរក្សាទំនាក់ទំនងជាមួយសម្ព័ន្ធភាព, ការធ្វើការជាមួយ

ប្រព័ន្ធផ្សព្វផ្សាយ, ការតស៊ូមតិតាមរយៈនីតិវិធីច្បាប់ និងការគៀងគរសហគមន៍។ បច្ចេកទេសនៃការធ្វើសកម្មភាពមានដូចជា ការបង្កើតផ្ទាំងរូបភាពតាមប្រព័ន្ធអ៊ីនធឺណែត ការរៀបចំកម្មវិធីផ្សាយតាមវិទ្យុ ចែកចាយព័ត៌មានតាមទូរទស្សន៍ និងស្ថានីយវិទ្យុ និងរៀបចំវេទិកាសាធារណៈ និងកិច្ចប្រជុំជាទៀងទាត់។ ក្រុមនេះទទួលបានយោបល់ថាគួរតែបញ្ចូលក្រសួងព័ត៌មានជាភាគីពាក់ព័ន្ធបន្ថែមទៀត ដោយសារតែការពាក់ព័ន្ធនឹងការធ្វើសេចក្ដីព្រាងច្បាប់ និងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងឧបករណ៍អ៊ីនធឺណែតផ្សេងៗទៀតក្នុងការផ្សព្វផ្សាយព័ត៌មាន។

### *សិទ្ធិដីធ្លី*

តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលផ្ដោតលើសិទ្ធិដីធ្លី កំណត់ **អនុសាសន៍១១៨.១២៩ និង ១១៨.១៣២** ជាអាទិភាពសម្រាប់អនុវត្ត និងតស៊ូមតិ។ ក្រុមនេះបានរកឃើញតិចនិចជាច្រើនដើម្បីសម្រេចគោលបំណងរបស់ខ្លួន ដោយរួមមានទាំងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ (ទាំងវិទ្យុជាតិ និង ឯកជនសារព័ត៌មានបោះពុម្ព ។ល។) ដើម្បីលើកកម្ពស់ការយល់ដឹង និងលើកយកបញ្ហាទៅក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងធនធានទឹក និងឧត្ដុនិយម, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏ដូចជាក្រសួងផ្សេងទៀតដែលមានវិសាលភាពពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច។ ក្រុមនេះក៏មានផែនការក្នុងការបញ្ចុះបញ្ចូលប្រទេសម្ចាស់ជំនួយឲ្យដាក់គំនាបសង្កត់ទៅលើរដ្ឋាភិបាលឲ្យអនុវត្តអនុសាសន៍ទាំងនេះដែរ។ ភាគីពាក់ព័ន្ធដែលនឹងចូលរួម រួមមាន ក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដោះស្រាយបញ្ហាសិទ្ធិដីធ្លី។

ក្រុមនេះនឹងតាមដានត្រួតពិនិត្យការអនុវត្តតាមរយៈការស្រាវជ្រាវ ឲ្យឃើញអ្នកណាជាអ្នករំលោភច្បាប់ទាក់ទងនឹងសិទ្ធិដីធ្លី និងថាតើច្បាប់ទាំងនេះត្រូវបានតុលាការអនុវត្តដែរឬទេ, ការតាមដានត្រួតពិនិត្យសកម្មភាព និងរបាយការណ៍ដែលធ្វើឡើងដោយក្រសួងពាក់ព័ន្ធ, តាមដានត្រួតពិនិត្យរបាយការណ៍ម្ចាស់ជំនួយ (ដែលច្រើនតែលើកឡើងអំពីបញ្ហាដីធ្លីមិនទាន់បានដោះស្រាយ), តាមដានត្រួតពិនិត្យលើប្រាក់កម្ចីដែលផ្ដល់ឲ្យដោយមានលក្ខខណ្ឌ, តាមដានត្រួតពិនិត្យតុលាការ និងថាតើតុលាការចេញសេចក្ដីសម្រេចយុត្តិធម៌ដែរឬទេ ទៅដល់ជនរងគ្រោះដោយសារការរំលោភសិទ្ធិដីធ្លី, តាមដានត្រួតពិនិត្យច្បាប់ពាក់ព័ន្ធនឹងដីធ្លី និងថាតើរដ្ឋាភិបាលបានគោរពការប្ដេជ្ញាចិត្តដែលបានធ្វើឡើងដែរឬទេ។

ផែនការយុទ្ធសាស្ត្ររបស់ក្រុមនេះ រួមមានធាតុជាច្រើន ៖ (១) ទទួលដំណឹងអំពីតំបន់ដែលមានបញ្ហាជម្លោះដីធ្លី, (២) រៀបចំប្រជាជនជាក្រុមឬជាសហគមន៍ដើម្បីពង្រឹងបណ្ដាញ និងសមត្ថភាព, (៣) រៀបចំកិច្ចប្រជុំតាមមូលដ្ឋាន និងវគ្គបណ្ដុះបណ្ដាលដែលអាចឲ្យប្រជាជនបានចេះដឹងអំពីច្បាប់, (៤) ផ្ដល់វគ្គបណ្ដុះបណ្ដាលអំពីច្បាប់ភូមិបាល ដើម្បីឲ្យប្រជាជនបានយល់ដឹងកាន់តែច្រើនអំពីសិទ្ធិដីធ្លី, និង (៥) យល់ដឹងអំពីស្តង់ដារអន្តរជាតិសម្រាប់

សិទ្ធិទទួលបានលំនៅឋានសមស្រប។ សកម្មភាពតស៊ូមតិដែលបានស្នើឡើងមានដូចជា ៖ (១) តាមដានត្រួត-ពិនិត្យ ការអនុវត្ត, (២) រៀបចំសិក្ខាសាលា និងកិច្ចប្រជុំដើម្បីពិភាក្សាអំពីបញ្ហាផ្សេងៗ, (៣) បោះពុម្ពផ្សាយរបាយការណ៍សិក្ខាសាលា និងកិច្ចប្រជុំដែលបានរៀបចំឡើង, (៤) បញ្ជូនព័ត៌មានដល់សាធារណជនដើម្បីឲ្យពួកគេបានដឹង តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងស្ថាប័នព័ត៌មានផ្សេងៗ, និង (៥) សម្របសម្រួលកិច្ចប្រជុំនៅកម្រិតមូលដ្ឋាន និងថ្នាក់ជាតិ។



### *សិទ្ធិស្ត្រី និងកុមារ*

តំណាងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតលើសិទ្ធិស្ត្រីនិងកុមារ កំណត់ **អនុសាសន៍១១៨.៧៦ និង ១១៨.១៦៧** ជាអាទិភាពសម្រាប់អនុវត្ត និងតស៊ូមតិ។ ក្រុមនេះបានរកឃើញគោលដៅសំខាន់បួន ដូចជា (១) ធ្វើឲ្យការអប់រំសម្រាប់កុមារមានភាពប្រសើរឡើង, (២) ផ្សព្វផ្សាយព័ត៌មានអំពីផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ និងប្រព័ន្ធអប់រំបច្ចុប្បន្ន, និង (៣) ធ្វើការជាមួយស្ថាប័នផ្សេងៗទៀតដើម្បីបង្កើតឲ្យមានប្រព័ន្ធអប់រំមួយដែលមានសមភាព។ ក្រុមនេះបានកំណត់នូវយុទ្ធសាស្ត្រតស៊ូមតិដូចតទៅ ៖ (១) បង្កើតបណ្តាញសម្រាប់តាមដានត្រួតពិនិត្យការអនុវត្ត ដោយរាប់បញ្ចូលទាំងការបង្រៀន និងការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ, (២) ដាក់របាយការណ៍ដល់រដ្ឋាភិបាល និងអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងស្ថានភាពនៃការអនុវត្ត, និង (៣) រៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលជាមួយមន្ត្រីក្រសួងពាក់ព័ន្ធ ដើម្បីពង្រឹងច្បាប់ និងការអនុវត្តច្បាប់។

ក្រុមនេះក៏បានសង្កត់ធ្ងន់អំពីតម្រូវការធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្រសួង និងអង្គការអន្តរជាតិ ដើម្បីអនុវត្តអនុសាសន៍ទាំងនោះ។ ភាគីពាក់ព័ន្ធសំខាន់ៗ ដែលក្រុមគេមានបំណងឲ្យចូលរួមជាមួយ មានដូចជា គ្រូបង្រៀន គ្រួសារ អង្គការមិនមែនរដ្ឋាភិបាល ក្រសួងនានារបស់រដ្ឋាភិបាលដែលធ្វើការពាក់ព័ន្ធនឹងបញ្ហាអប់រំ និងភាគីពាក់ព័ន្ធផ្សេងទៀត។ ក្រុមនេះនឹងស្វែងរកការសហប្រតិបត្តិការបន្ថែម និងបង្កើតអនុស្សរណៈយោគយល់ជាមួយរដ្ឋាភិបាលក្នុងគោលបំណងតាមដានព័ត៌មាន អំពីវិធានការរបស់រដ្ឋាភិបាលសំដៅអនុវត្តអនុសាសន៍ និងរបៀបដែលអង្គការមិនមែនរដ្ឋាភិបាលអាចសហការណ៍គ្នាបាន។

សកម្មភាពតស៊ូមតិសំខាន់ៗដែលក្រុមនេះកំណត់ រួមមាន ៖ (១) រៀបចំកិច្ចប្រជុំជាមួយស្ថាប័នអប់រំ, (២) ចូលរួមកិច្ចប្រជុំដែលនឹងរួមចំណែកដល់ការកែលម្អគោលនយោបាយអប់រំ, (៣) សហការណ៍ជាមួយប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សព្វផ្សាយព័ត៌មាន និងឲ្យប្រជាពលរដ្ឋចូលរួម, (៤) បង្កើតបណ្តាញថ្មីៗនៅកម្រិតមូលដ្ឋាន, (៥) តាមដានត្រួតពិនិត្យការអនុវត្តផែនការអប់រំ, និង(៦) ចេញផ្សាយរបាយការណ៍ដែលមានរបកគំហើញចេញពីសកម្មភាពតាមដានត្រួតពិនិត្យ។

## *សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌*

តំណាងអង្គការមិនមែនរដ្ឋាភិបាលដែលផ្តោតលើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ កំណត់ **អនុសាសន៍ ១១៨.១២៦ និង ១១៨.១៤៣** ជាអាទិភាពសម្រាប់អនុវត្ត និងតស៊ូមតិ។ ក្រុមនេះបានរកឃើញយុទ្ធសាស្ត្រចំនួនបីគឺ៖ (១) សហការណ៍ជាមួយរដ្ឋាភិបាល តាមរយៈផ្តល់ការបណ្តុះបណ្តាលបច្ចេកទេស និងចែករំលែកចំណេះដឹង, (២) ជំរុញឲ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ តាមរយៈការរៀបចំសិក្ខាសាលាថ្នាក់ជាតិ និងអន្តរជាតិ, និង (៣) ផ្តល់ថវិកាដល់រដ្ឋាភិបាលដើម្បីអនុវត្តអនុសាសន៍ទាំងនោះ។ ក្រុមនេះបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការតាមដានការអនុវត្តអនុសាសន៍របស់រដ្ឋាភិបាល។

ភាគីពាក់ព័ន្ធដែលត្រូវបានកំណត់ រួមមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ។

## *អនុសាសន៍របស់លោកស្រីក្លូង សម្រាប់ក្រុមពិភាក្សា*

នៅចុងបញ្ចប់នៃថ្ងៃទីមួយ ដើម្បីឆ្លើយតបចំពោះក្រុមពិភាក្សា លោកស្រីក្លូង បានបញ្ជាក់ ផ្តល់យោបល់ និងលើកសំណើសម្រាប់ក្រុមពិភាក្សាទាំងអស់។ ជាដំបូង លោកស្រីបញ្ជាក់ថា នៅពេលរដ្ឋាភិបាលត្រូវដាក់របាយការណ៍នោះ អ្វីដែលសំខាន់គឺរបាយការណ៍នោះជារបាយការណ៍របស់រដ្ឋាភិបាល។ សង្គមស៊ីវិលអាចផ្តល់យោបល់ត្រឡប់ និងគំនិតរបស់ខ្លួន ប៉ុន្តែសង្គមស៊ីវិលនីមួយៗត្រូវដាក់របាយការណ៍របស់ខ្លួនផ្ទាល់ ដើម្បីឲ្យមានភាពជាម្ចាស់ក្នុងការដាក់របាយការណ៍នីមួយៗ។ ការផ្តោតចំណាប់អារម្មណ៍ គួរតែផ្តោតលើអនុសាសន៍ដែលបានទទួលយកបានហើយ ពីព្រោះថា អនុសាសន៍ដែលកត់សម្គាល់ មានន័យថា រដ្ឋាភិបាលមិនបានប្តេជ្ញាចិត្តក្នុងការអនុវត្តនោះទេ។

លោកស្រីក្លូងបានកត់សម្គាល់ថា អ្នកចូលរួមគួរផ្សព្វផ្សាយឲ្យបានច្រើនតាមដែលអាចធ្វើទៅបាននូវអនុសាសន៍ដែលពួកគេបានផ្តល់ជាអាទិភាព ហើយថាពួកគេត្រូវគិតអំពីរបៀបផ្សេងទៀតក្នុងការផ្សព្វផ្សាយអនុសាសន៍ទាំងនោះ។ ឧទាហរណ៍ ប្រសិនបើអង្គការសង្គមស៊ីវិលដាក់អនុសាសន៍ដែលពួកគេផ្តល់អាទិភាពនៅលើគេហទំព័រនោះ ក៏អាចជាការចាប់ផ្តើមដ៏ល្អមួយរួចទៅហើយ។ លោកស្រីបានផ្តល់យោបល់ថា ក្រុមជាច្រើនបានលើកឡើងពីការដាក់គំនាបលើរដ្ឋាភិបាលរបស់ប្រទេសម្ចាស់ជំនួយ ម្ចាស់ជំនួយអាចជាមធ្យោបាយមួយក្នុងការដាក់គំនាប និង

ផ្តល់ការគាំទ្របន្ថែម ប៉ុន្តែ គេត្រូវផ្តោតទៅលើប្រជាពលរដ្ឋកម្ពុជាក្នុងការដាក់សម្ពាធទៅលើរដ្ឋាភិបាលរបស់ខ្លួន និងតាមដានការអនុវត្ត។

លោកស្រីកត់សម្គាល់ថា ផែនការរបស់ក្រុមមួយចំនួនមានភាពស្រពេចស្រពិលណាស់។ ឧទាហរណ៍ សម្រាប់ការតាមដានករណីដីធ្លី ពួកគេគួរគិតអំពីរបៀបប្រមូលឯកសារអំពីករណីទាំងនោះ ដូចជាការបង្កើតប្រព័ន្ធទិន្នន័យជាដើម។ លោកស្រីបានស្នើឡើងថាអង្គការត្រូវការមធ្យោបាយដែលមានលក្ខណៈជាប្រព័ន្ធមួយដើម្បីតាមដានរដ្ឋាភិបាល។ នេះក៏ជាបញ្ហាសម្រាប់វគ្គទីមួយដែរ អង្គការទាំងអស់និយាយថា រដ្ឋាភិបាលមិនបានអនុវត្តអនុសាសន៍ទេ ប៉ុន្តែអ្វីដែលយើងត្រូវការគឺទិន្នន័យ។ ដូច្នេះប្រសិនបើប្រជាពលរដ្ឋនិយាយថារដ្ឋាភិបាល មិនបានអនុវត្តអនុសាសន៍ពួកគេត្រូវមានទិន្នន័យពិតប្រាកដសម្រាប់គាំទ្រការលើកឡើងរបស់ពួកគេ។ លោកស្រីសូមឲ្យអ្នកចូលរួមចងចាំថា ពួកគេគួរជ្រើសរើសអនុសាសន៍ដែលសំខាន់បំផុតសម្រាប់ពួកគេ។ នៅពេលដែលអង្គការ មានអនុសាសន៍ច្រើន តើគេអាចចាប់ផ្តើមអនុសាសន៍ណាមួយមុន? សូម្បីតែការអនុវត្តអនុសាសន៍មួយជាការលំបាកទៅហើយ ដូច្នេះប្រសិនបើមានអនុសាសន៍តែមួយចំនួនត្រូវបានអនុវត្តនោះ នេះជាចំណុចវិជ្ជមានរួចហើយ។

លោកស្រីបានថ្លែងថា អង្គការ គួរបញ្ជាក់ឲ្យច្បាស់ពីប្រភេទនៃការគាំទ្រដែលពួកគេអាចផ្តល់ឲ្យរដ្ឋាភិបាល។ តើមាន "ជំនួយ" ប្រភេទណាខ្លះដែលពួកគេនឹងផ្តល់ឲ្យ? ឧទាហរណ៍ អង្គការអាចផ្តល់អនុសាសន៍ ឬធ្វើការស្រាវជ្រាវច្បាប់ ឬការអនុវត្តក្នុងប្រទេសដទៃទៀត។ អ្នកចូលរួមគួរតែមានភាពច្បាស់លាស់ចំពោះគោលដៅរបស់ខ្លួន និងរបៀបដែលពួកគេធ្វើផែនការគាំទ្ររដ្ឋាភិបាល។ ពួកគេគួរតែមានភាពប្រាកដប្រជា ដោយសារតែយើងនិយាយតែអំឡុងពេល ៤,៥ ឆ្នាំ តែប៉ុណ្ណោះ។ លោកស្រីបានជំរុញឲ្យអ្នកចូលរួមជ្រើសរើសជម្រើសមួយចំនួនដែលពួកគេចង់ផ្តោតទៅលើនាឆ្នាំខាងមុខ ពីរឆ្នាំខាងមុខ និងបីឆ្នាំខាងមុខ ដោយជ្រើសរើសអនុសាសន៍ពីបីទៅប្រាំ ហើយប្រឹងប្រែងធ្វើបន្ថែមទៀតទៅលើអនុសាសន៍ទាំងនោះ។

ពេលកំណត់បានអនុសាសន៍ជាអាទិភាពហើយ លោកស្រីក្លូងបានពន្យល់ថាជំហានបន្ទាប់គួរត្រូវរកឲ្យឃើញអំពីរបៀបធ្វើការជាមួយដៃគូដែលបានកំណត់ទាំងនោះ ដែលអាចរួមមានការសរសេរទៅកាន់ដៃគូទាំងនោះ ដើម្បីសុំឲ្យមានការជួបប្រជុំ និងរកឲ្យឃើញអំពីចំណុចដែលត្រូវពិភាក្សាជាដើម។ អ្នកចូលរួមគួរគិតថាតើស្ថាប័នណាខ្លះមានភាពបើកចំហជាង ស្ថាប័នណាខ្លះដែលមានប្រយោជន៍ជាង និងស្ថាប័នណាខ្លះដែលពួកគេគិតថានឹងជាដៃគូមានប្រសិទ្ធភាពក្នុងការអនុវត្តការផ្លាស់ប្តូរជាង។ បណ្តាញ និងក្រុមការងារក៏អាចមានប្រយោជន៍ផងដែរ ព្រោះថាបើធ្វើរួមគ្នាអាចធ្វើឲ្យអង្គការកាន់តែរឹងមាំ កាន់តែមានប្រសិទ្ធភាព និងកាន់តែមានអំណាច។ ការប្រមូលព័ត៌មានជាបញ្ហាកំពុងប្រឈមដ៏ធំមួយក្នុងប្រទេសកម្ពុជា។ ការមានទិន្នន័យព័ត៌មានទាំងនេះនឹងមានប្រយោជន៍សម្រាប់វគ្គបន្ទាប់នេះ។

ពាក់ព័ន្ធនឹងតិចនិច លោកស្រីបានថ្លែងថា ការរៀបចំសន្និសីទសារព័ត៌មានដែលមានការរិះគន់ចំពោះការរំលោភបំពាន ជាទង្វើមានប្រយោជន៍ក្នុងករណីមួយចំនួន ប៉ុន្តែ ការធ្វើបែបនេះមិនមែនតែងតែបង្កឲ្យមានការសន្ទនា

បែបស្ថាបនាជាមួយរដ្ឋាភិបាលនោះទេ។ លោកស្រីបានស្នើឡើងថាត្រូវតែរកតុល្យភាពឲ្យសមស្របមួយ រវាងទង្វើបែបស្ថាបនា និងបែបរិះគន់ផងដែរ។ ឧទាហរណ៍ អង្គការ អាចស្នើដល់រដ្ឋាភិបាលអំពី*របៀប* ដែលពួកគេគួរផ្លាស់ប្តូរនៅក្នុងក្រមព្រហ្មទណ្ឌ មិនមែនគ្រាន់តែថាគួរផ្លាស់ប្តូរនោះទេ។ លោកស្រីបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការបង្កើតគំនិតរឹងមាំមួយចំនួន ដូចជា ប្រសិនបើចង់បង្កើនការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី គំនិតមួយចំនួនអាចរួមមានដូចជាការចែកខិត្តប័ណ្ណអំពីសិទ្ធិ និងការទទួលបានមេធាវី ការធ្វើសារជាអក្សរ ការអប់រំស្ត្រីអំពីច្បាប់ និងការរៀបចំសិក្ខាសាលា ឬវគ្គបណ្តុះបណ្តាលឲ្យទៅស្ត្រីជាដើម។

លោកស្រីក្លូងបានបញ្ចប់ដោយកត់សម្គាល់ថាអ្នកចូលរួម ត្រូវគិតអំពីសកម្មភាពដែលពួកគេអាចអនុវត្តបានចាប់ពីពេលនេះទៅ ដើម្បីចាប់ផ្តើមដំណើរការនៃការអនុវត្តនេះ។ ពួកគេទាំងអស់អាចជ្រើសរើសយកអនុសាសន៍មួយ និងប្រើអនុសាសន៍នោះឲ្យបានច្រើនតាមដែលអាចធ្វើទៅបានក្នុងកិច្ចប្រឹងប្រែងធ្វើការតស៊ូមតិ និងនៅពេលពួកគេជជែកជាមួយដៃគូការងារ។ អ្នកចូលរួមត្រូវតែរំលឹកដល់រដ្ឋាភិបាលជាប្រចាំអំពីអនុសាសន៍នេះ នៅគ្រប់ពេលដែលធ្វើទៅរួច។

# សេចក្តីសន្និដ្ឋាន

ការប្រើប្រាស់យន្តការ អ.ស.ប ដូចជាការរាយការណ៍ទៅស្ថាប័នកតិកាសញ្ញា ការដាក់ពាក្យបណ្តឹង និងការដាក់បណ្តឹងបុគ្គល ដោយសង្គមស៊ីវិលនៅកម្ពុជា ស្ថិតនៅក្នុងដំណាក់ក្មេងខ្ចីនៅឡើយ។ ក៏ប៉ុន្តែ អង្គការ និងសង្គមស៊ីវិលកម្ពុជា កំពុងតែបង្កើនការប្រើប្រាស់វិធីសាស្ត្រទាំងនេះសម្រាប់ការតស៊ូមតិ ដែលជាផ្នែកមួយនៃការងាររបស់ខ្លួន ក្នុងការធ្វើឲ្យមានការរីកចម្រើនដល់សិទ្ធិមនុស្សក្នុងប្រទេសនេះ។ ម.ស.ម.ក ជឿជាក់យ៉ាងមុតមាំថា កាលណាសង្គមស៊ីវិលកាន់តែប្រើយន្តការទាំងនេះឲ្យបានទូលំទូលាយ និងកាន់តែមានលក្ខណៈជាប្រព័ន្ធនោះ នឹងកាន់តែជួយដាក់គំនាបទៅលើរដ្ឋាភិបាលឲ្យអនុវត្តអនុសាសន៍ទាំងនោះ។ កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិបន្ទាប់ពី យូភីអ ត្រូវបានរៀបចំឡើងក្នុងគោលបំណងណែនាំបង្ហាញដល់អង្គការមួយចំនួនអំពីដំណើរការ យូភីអ និងមានគោលបំណងកសាងសមត្ថភាពឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត ក្នុងចំណោមអ្នកចូលរួម មិនមែនត្រឹមតែអំពីរបៀបដែលដំណើរការនេះប្រព្រឹត្តទៅនោះទេ ថែមទាំងរបៀបដែលសង្គមស៊ីវិលអាចចូលរួមក្នុងដំណើរការនេះបានទៀតផង។

មតិយោបល់ត្រឡប់ពីអ្នកចូលរួមមានលក្ខណៈវិជ្ជមានជាទូទៅ។ អ្នកចូលរួមបានលើកឡើងថាពួកគេបានរៀនសូត្រចេះដឹងទាំងពីបទបង្ហាញ និងការពិភាក្សារបស់វាគ្មិន ទាក់ទងនឹងដំណើរការ យូភីអ និងពីការពិភាក្សាក្នុងក្រុម ជាពិសេសទាក់ទងនឹងសារៈសំខាន់នៃការអំពាវនាវឲ្យរដ្ឋាភិបាលអនុវត្តអនុសាសន៍ អំពីរបៀបដែលភាគីពាក់ព័ន្ធអាចចូលរួមក្នុងដំណើរការ យូភីអ និងអំពីរបៀបកំណត់អនុសាសន៍ជាអទិភាព។ ក៏ប៉ុន្តែ អ្នកចូលរួមមានអារម្មណ៍ថា ការពិគ្រោះយោបល់នេះនឹងកាន់តែមានប្រយោជន៍ ប្រសិនបើមានតំណាងរដ្ឋាភិបាលចូលរួមក្នុងការពិគ្រោះយោបល់លើសពីការគ្រាន់តែចូលរួមថ្លែងសុន្ទរកថាស្វាគមន៍នោះ ហើយនឹងកាន់តែល្អប្រសិនបើទុកពេលបានច្រើនជាងនេះក្នុងការសួរឆ្លើយ។ អ្នកចូលរួមបានលើកឡើងថាពួកគេនឹងយកអ្វីដែលពួកគេបានចេះដឹងពីកិច្ចពិគ្រោះយោបល់នេះទៅចែករំលែកតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ចែកព័ត៌មានដល់ដៃគូផ្សេងទៀត តាមដានត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការអនុវត្តអនុសាសន៍ យូភីអ និងតស៊ូមតិជាមួយរដ្ឋាភិបាលពាក់ព័ន្ធនឹងការអនុវត្ត។

ដោយសារតែ យូភីអ ទីបីសម្រាប់ប្រទេសកម្ពុជានឹងត្រូវធ្វើឡើងជាងបួនឆ្នាំខាងមុខទៀត គឺក្នុងខែតុលា ២០១៨ នោះ នេះជាពេលដ៏សក្តិសមមួយក្នុងការចាប់ផ្តើមការតាមដានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល ឬកង្វះខាតក្នុងការអនុវត្តអនុសាសន៍ យូភីអ នេះ។ ចំណុចនេះក៏សំខាន់ដែរដែលសង្គមស៊ីវិលត្រូវតស៊ូមតិឲ្យបានសកម្មដើម្បីឲ្យមានការអនុវត្ត និងដើម្បី ដាក់ការងារនេះចូលទៅក្នុងផែនការ និងសកម្មភាពតស៊ូមតិដែលមានស្រាប់របស់ខ្លួន។

## ឧបសម្ព័ន្ធទី១ ៖ អនុសាសន៍ដែលផ្តល់អាទិភាពដោយអ្នកចូលរួម

**១១៨.១៧** បង្កើតច្បាប់មួយស្តីពីសេរីភាពព័ត៌មាន យោងតាមស្តង់ដារអន្តរជាតិ (បែលហ្សិក)

**១១៨.១៨** អនុម័តវិធានការច្បាប់ និងវិធានការដទៃទៀត ដែលលើកកម្ពស់ការទទួលបាន សេរីភាពក្នុងការបញ្ចេញមតិ (បូតស្វាណា)

**១១៨.១៩** ចាត់វិធានការដើម្បីធានាថា ច្បាប់កម្ពុជាអនុញ្ញាតឲ្យគណបក្សនយោបាយ ទាំងអស់ សហជីព និងក្រុមសង្គមស៊ីវិល ប្រើប្រាស់សិទ្ធិរបស់ខ្លួនដើម្បីទទួលបាន សេរីភាពក្នុងការបញ្ចេញមតិ ការបង្កើតសមាគម និងការប្រមូលផ្តុំដោយសន្តិវិធី ហើយថាបាតុកម្មដោយសន្តិវិធី អាចកើតឡើងដោយសុវត្ថិភាព ដោយគ្មានការភ័យខ្លាច អំពីការបំផិតបំភ័យ ឬការប្រើកម្លាំងហួសហេតុពីខាងភាគីអាជ្ញាធរកម្ពុជា។ (កាណាដា)

**១១៨.២០** កែសម្រួលក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ដទៃទៀត ដើម្បីឲ្យអនុលោមតាម ស្តង់ដារអន្តរជាតិទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិ និងទប់ស្កាត់ការរំខានដល់ អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងអង្គការក្រៅរដ្ឋាភិបាល (សាធារណរដ្ឋឆេក)

**១១៨.២៣** ចាត់វិធានការចាំបាច់នានា ដើម្បីពង្រឹងក្របខ័ណ្ឌច្បាប់ជុំវិញការបោះឆ្នោត ក្នុងគោលបំណងធានាថា ការបោះឆ្នោតក្នុងពេលអនាគត មានលក្ខណៈសេរី និង យុត្តិធម៌ ដែលអនុញ្ញាតឲ្យពលរដ្ឋកម្ពុជា មានសម្លេងនៅក្នុងការសម្រេចចិត្តនានា ដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ និងជ្រើសរើសមន្ត្រីដែលឆ្លុះបញ្ចាំង និងឆ្លើយតប ដោយប្រសិទ្ធភាពទៅនឹងតម្រូវការរបស់ពួកគេ (កាណាដា)

**១១៨.៧៦** បង្កើនទ្វេដងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ (អេក្វាឌ័រ)

**១១៨.១២៦** បន្តពង្រឹងកម្មវិធីបង្កើតការងារប្រកបដោយប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំង ភាពក្រីក្រ និងវិសមភាពក្នុងសង្គម (វេនេហ្ស៊ុយអេឡា (សាធារណរដ្ឋបូលីវី))

**១១៨.១២៩** បញ្ឈប់ការដកហូតដោយបង្ខំ និងធានាដំណើរការប្រកបដោយយុត្តិធម៌ និង តម្លាភាព ទាក់ទងទៅនឹងសិទ្ធិប្រើប្រាស់ដីធ្លី (មិកហ្ស៊ិក)

**១១៨.១៣២** ធានាថា ការផ្តល់សម្បទានដី ឬការដកហូតកម្មសិទ្ធិដី ឬសិទ្ធិស្របច្បាប់ក្នុង ការប្រើប្រាស់ដីធ្លី មិនបង្កឲ្យមានអំពើរំលោភសិទ្ធិមនុស្ស (អាល្លឺម៉ង់)

**១១៨.១៤៣** សហការជាមួយសហគមន៍អន្តរជាតិ អនុវត្តកម្មវិធីនានាប្រកបដោយប្រសិទ្ធភាព សំដៅកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅក្នុងតំបន់ជនបទនៃប្រទេស (អាហ្សែបៃហ្សង់)

**១១៨.១៦៧** បន្តធ្វើការលើផែនការជាតិរបស់ខ្លួន ស្តីពី "ការអប់រំសម្រាប់ទាំងអស់គ្នា" ដើម្បី ឲ្យកុមារ និងយុវជនកម្ពុជាទាំងអស់ ទទួលបានសេវាអប់រំប្រកបដោយសមធម៌ (មីយ៉ាន់ម៉ា)

## ឧបសម្ព័ន្ធ២ ៖ របៀបវារៈនៃការពិគ្រោះយោបល់

**ថ្ងៃទី១ - ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ៖ ការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ (យូភីអ)**

៨.០០ ព្រឹក ការមកដល់របស់អ្នកចូលរួម និងការចុះឈ្មោះ

៨.៣០ ព្រឹក **ការគោរពភ្លេងជាតិ**

**សុន្ទរកថាបើកកម្មវិធី**

លោកស្រី **ជរ ច័ន្ទធីតា** អ្នកស្រាវជ្រាវជាន់ខ្ពស់ និងជាសមាជិកគណៈកម្មការគ្រប់គ្រងរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

លោកស្រី **វ៉ាន់ហ៊ី លី** អ្នកតំណាង ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ឯកឧត្តម **ម៉ក់ សម្បត្តិ** ប្រធាន នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក)

៩.០០ព្រឹក បទបង្ហាញ ស្តីពី យន្តការ យូភីអ និងការពិនិត្យមើលលើអនុសាសន៍ ដែលកម្ពុជាបានទទួលក្នុងដំណើរការ យូភីអ

លោកស្រី **ខាធីរីន ភួង** អ្នកសម្របសម្រួលផ្នែកនីតិរដ្ឋ នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

១០.០០ព្រឹក សម្រាកអាហារសម្រន់

១០.២០ព្រឹក កិច្ចពិភាក្សា ស្តីពី "ការអនុវត្តអនុសាសន៍ យូភីអ"

សម្របសម្រួលដោយ ៖ កញ្ញា សន រ៉ាមណា, អ្នកសម្របសម្រួលគម្រោង, ម.ស.ម.ក

វាគ្មិនកិត្តិយស ៖

១. លោក មាស សំណាង, អគ្គលេខាធិការ, សម្ព័ន្ធអង្គការស្តីពីសិទ្ធិកុមារ (ស.ក.ស.អ)

២. លោក អ៊ូ វីរៈ ប្រធានក្រុមប្រឹក្សាភិបាល មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

៣. លោក សួន ប៊ុនសក្តិ, លេខាប្រតិបត្តិ, គណៈកម្មការប្រព្រឹត្តកម្មអង្គការសមាគម សិទ្ធិមនុស្សនៅកម្ពុជា

វាគ្មិននឹងពិភាក្សាលើបញ្ហាដូចជា ៖

- ការត្រួតពិនិត្យការអនុវត្តអនុសាសន៍
- តួនាទីរបស់ស្ថាប័នផ្សេងៗក្នុងការអនុវត្តអនុសាសន៍
- បទពិសោធន៍របស់អង្គការនីមួយៗ ក្នុងដំណើរការ យូភីអ (ក្នុងសម័យប្រជុំមុន)
- ការត្រៀមខ្លួនសម្រាប់ការត្រួតពិនិត្យពាក់កណ្តាលវគ្គ

១២.០០ថ្ងៃត្រង់ សម្រាកទទួលទានអាហារថ្ងៃត្រង់

១.៣០រសៀល កិច្ចពិភាក្សាក្រុមតូចទៅលើ អនុសាសន៍ យូភីអ ចែកតាមប្រធានបទដូចខាងក្រោម ៖

១. សិទ្ធិដីធ្លី

២. សិទ្ធិសេរីភាពបញ្ចេញមតិ

៣. សិទ្ធិស្ត្រី និងសិទ្ធិកុមារ

៤. កំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌

៥. សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

៣.១៥រសៀល សម្រាកអាហារសម្រន់

៣.៣០រសៀល ការរាយការណ៍ពីក្រុមតូច និងការពិភាក្សាក្រុមធំ

អ្នកសម្របសម្រួល ៖ អ្នកស្រី **ជរ ច័ន្ទធីតា** អ្នកស្រាវជ្រាវជាន់ខ្ពស់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មតិយោបល់ត្រលប់ ៖ វាគ្មិនកិត្តិយស និង លោកស្រី ខាធីរីន ក្លូង អ្នកសម្របសម្រួលផ្នែកនីតិរដ្ឋ នៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

៤.៣០ល្ងាច បញ្ចប់ថ្ងៃទី១

**ថ្ងៃទី២ - ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ៖ យុទ្ធសាស្ត្រតស៊ូមតិដើម្បីអនុវត្តអនុសាសន៍ យូភីអ**

៨.០០ព្រឹក ការមកដល់របស់អ្នកចូលរួម និងការចុះឈ្មោះ

៨.៣០ព្រឹក បទបង្ហាញស្តីពីការបង្កើតផែនការយុទ្ធសាស្ត្រដើម្បីធ្វើការតស៊ូមតិ

លោក **ឡាំ សុជាតិ** នាយកប្រតិបត្តិរង នៃវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ

៩.៤៥ព្រឹក សម្រាកអាហារសម្រន់

១០.០០ព្រឹក កិច្ចពិភាក្សាក្រុមតូចស្តីពីយុទ្ធសាស្ត្របង្កើតផែនការតស៊ូមតិ

១២.០០ថ្ងៃត្រង់ សម្រាកទទួលទានអាហារថ្ងៃត្រង់

១.៣០រសៀល ការរាយការណ៍ពីក្រុមតូច និងការពិភាក្សាក្រុមធំ

អ្នកសម្របសម្រួល ៖ កញ្ញា សន រ៉ាមណា អ្នកសម្របសម្រួលគម្រោង ម.ស.ម.ក

២.៣០រសៀល វគ្គសិក្ខាសាលា៖ យុទ្ធសាស្ត្រដើម្បីអនុវត្តអនុសាសន៍ឲ្យមានប្រសិទ្ធភាព និងមេរៀនពីប្រទេសដទៃ

លោកស្រី ហ្វ្រង់ហ្សេស្កា ពីហ្ស៊ីន អ្នកគ្រប់គ្រងកម្មវិធី យូភីអ អ៊ីនហ្វូ

៣.៣០រសៀល បិទកម្មវិធី

## ឧបសម្ព័ន្ធទី៣ ៖ អង្គការចូលរួម

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍន៍កម្ពុជា និងការស្តារឡើងវិញសម្រាប់ជនក្រីក្រ
សហគមន៍យុវជនជនជាតិដើមភាគតិចកម្ពុជា
មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ
ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
អង្គការជនពិការកម្ពុជា
គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍
ភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា
សហប្រតិបត្តិការដើម្បីការកសាងសមត្ថភាពសម្រាប់ជនពិការ មជ្ឈមណ្ឌលខេមរសិក្សា
គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា
ក្រុមការងារពង្រឹង និងអភិវឌ្ឍសហគមន៍
បណ្តាញកសាងសន្តិភាពសម្រាប់សហគមន៍
អភិរក្ស និងអភិវឌ្ឍន៍នៅកម្ពុជា
គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
អង្គការខារ៉ាមកម្ពុជា
អង្គការសមធម៌កម្ពុជា
ក្រុមការពារពិសេសការពារសិទ្ធិលំនៅឋាន
សមាគមឥន្ទ្រទេវី
សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ
វិទ្យាស្ថានខ្មែរសម្រាប់អភិវឌ្ឍន៍ជាតិ
សហគមន៍ខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍ ជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី
វិទ្យាស្ថានជាតិអប់រំ
ការផ្តួចផ្តើមថ្មីដើម្បីជីវភាព និងសុខភាព
សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ដៃគូផ្តល់មេត្តា
មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព
អង្គការលើកស្ទួយប្រជាពលរដ្ឋ
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
សន្និសេនា
ស្ពានកម្ពុជា
អង្គការតម្លាភាពអន្តរជាតិ កម្ពុជា
អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង
នារីដើម្បីសន្តិភាព
យុវសន្តិភាព
យុវជនដើម្បីការអភិវឌ្ឍន៍នៅកម្ពុជា
កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន